ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

## ១៧ ១

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកគ្រូតព្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

### ផ្នែកអក្សរសាស្ត្រ

ទំព័រ

ឃុនបញ្ញាសោភ័ន គាំ-ឌុម . . . ពតិមាន ថ្លែងសេចក្ដីកាលទៅនាំយកព្រះពុទ្ធរូបនឹងបល្លង្ក នៅឃុំអង្គរបូរី (តាកែវ) ១

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម. . . . រឿងភ៉ីរបស់លោកធុតង្គ ជាតិចិន ១ រូប ឈ្មោះ ហ៊ូន-ផាង . . . . . . . . . ១៥

. . . . . . . . . . . . . . ច្បាប់ព្រះបន្ទូលវែង . . . . . . . . . . ២៥

ព្រះគ្រូមុនីសោភ័ន សោម-ឡុប នានាភាសិត . . . . . . . . . . . . ៣៣

### ផ្នែកសាសនា

ដំណឹងអំពីក្រសួងធម្មការ. . . . . ការប្រជុំលោកមេគណនឹងអនុគណ នៅវត្តសារាវ័ន . . . . . . . . . . . . . ៣៩

លោកគ្រូអាចារ្យ ប៉ាង-ខាត់. . . . អរិយសច្ច ជាពុទ្ធភាសិត. . . . . . . . ៤២

ឆ្នាំទី ១៧ — លេខ ១ ខែយ៉ាំងវីយេ ឆ្នាំ ១៩៤៥ — ដំឡៃជាវ: ១ ឆ្នាំ ១៥ រៀល ។

# KĂMPUCHĔASŌRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire: Luong Nibandhamantr
NHOK-THÈM, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse: Preah kru Pannalikhito
KAO-SIM, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

**Partie littéraire:**

| | | Pages |
|---|---|---|
| K'ŭn Panhnha sòp'ĕaa Kam-Doum . . . . . | Rapport sur le transfert des statues de Bouddha d'Angkorborei (Takèv) à Phnôm-Penh. . . . | 1 |
| Luong Nĭponmontrei Nhok-Thêm. . . . . . | Récit d'un Pèlerin chinois Huoun-Tsang tiré du livre "Religieux et Pèlerins en Terre d'Asie" . . | 15 |
| . . . . . . . . . . . | Chbăp prĕah băntul chèng, poème | 25 |
| Prĕah kru mŭnisòp'ĕan Sòm-Loch. . . . . . | Neaneap'easĕt. . . . . . . . . . . . | 33 |

**Partie religieuse:**

| | | |
|---|---|---|
| Communiqné du Département des Cultes. . . . | Réunion des Mékons et des Anŭkons à Vĕat Saravĕan (P. Penh) | 39 |
| Vén. Achar Pang-Khat. . . | Ariyasaccā — Buddhabhāsitā . . . | 52 |

17e Année — N° 1. Janvier 1945 — Abonnement: un an 15$00.

ពត៌មានថ្លែងសេចក្ដី

កាលទៅនាំយកព្រះពុទ្ធរូបថ្មបល្ល័ង្កនៅឃុំអង្គរបុរី ស្រុកព្រៃកប្បាស

ខែត្រតាកែវ ខែសេបតម្ប៍ ១៩៤៤

# ឃុន បញ្ញាសោភ័ណ គាំ-ឌុម រៀបរៀង

គ្រប់ប្រទេសក្នុងលោកសព្វថ្ងៃ រមែងមានសារមន្ទីរ ១ ឬ ២ ជាដើមទៅ សម្រាប់ប្រមូលយកបុរាណវត្ថុទាំងប៉ុន្មានដែលមានក្នុងស្រុករបស់ខ្លួន ឬក៏ទិញយកមកអំពីប្រទេសក្រៅខ្លះ មកដំកល់ទុកជាទីទស្សនាការដល់ពួកប្រជាជនតកាល (ជនដែលកើតមានក្រោយ) ក្នុងប្រទេសនោះៗ ទាំងជនជាតិប្រទេសដទៃ ដែលត្រូវការចូលទៅមើលដោយប្រាថ្នាចង់ដឹង-ស្គាល់ អស់ទាំងបុរាណវត្ថុក្នុងប្រទេសនោះៗផង ដើម្បីរក្សាទុកកុំឲ្យវិនាសបាត់បង់ទៅ អស់ទាំងបុរាណវត្ថុដែលជាកេរ្តិ៍ដំណែលនៃបុព្វបុរសរបស់ប្រទេសនោះៗ ដែលបានធ្វើទុកជាយូរអង្វែងមកហើយផងៗ

អាស្រ័យដោយហេតុដូចនិយាយមកខាងលើនេះហើយ បានជាលោក ឌុយប៉ុងត៍ ជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ជាអធិបតីនៃសារមន្ទីរអាល់ប៊ែរសារ៉ូត៍ ភ្នំពេញ ដែលជាមេគ្រប់គ្រងរក្សា អស់ទាំងបុរាណវត្ថុក្នុងស្រុកខ្មែរទាំងប៉ុន្មាន បានចាត់ប្រើយើងខ្ញុំទាំង ៤ នាក់គឺ: គាំ-ឌុម, គី-គឹមស៊ុំ, អ៊ុក-សេន, សៅ-សឿន ឲ្យធ្វើដំណើរចេញពី

កំណាត់ត្រាប់១ការុង ប្រាក់១កន្ទុយថែមទៀត ព្រមទាំងយកដែក ដំដែកទៅផុតដំឲ្យស្រួចខ្លះឲ្យសំប៉ែតខ្លះជម្រៃតាមការដែលត្រូវធ្វើ ។

ថ្ងៃ៤ ដេសេមប្រ៍ វេលាម៉ោង៩ព្រឹក ព្រះបាទម្ចាស់ទៅហាយវែត្រ ទីនិងលោកឡឺរេស៊ីដង់ ចាត់ប្រើឲ្យពួកអ្នកទោសជញ្ជូនគ្រឿងដែកនិង ឈើពីសាធារណការស្ថានទៅផ្ទុកក្នុងទូក ១ ដែលជួលពីចិនម្នាក់នៅផ្សារ តាកែវបំរុងនឹងយកទៅនាំយកព្រះពុទ្ធរូបជាដើម ដល់ថ្ងៃល្ងាចម៉ោង៦ ទើបផ្ទុកហើយជាស្រេច ។ ចំណែកលោកវិស្សុកម្មនឹងពួកវិស្សុកម្ម៥នាក់ ក្រោមបង្គាប់របស់លោក ដែលបំរុងនឹងទៅជួយចាត់ការយកព្រះពុទ្ធរូប ជាដើម ជាមួយនឹងពួកយើងខ្ញុំដែរនោះ បាននិយាយថាឲ្យយើងខ្ញុំ ចេញទៅចាត់ការមុនចុះ ដល់ថ្ងៃ៨ដេសេមប្រ៍ ទើបលោកនាំគ្នាទៅ ជាខាងក្រោយ ឯយើងខ្ញុំទាំង៤នាក់ព្រមទាំងទាហាន៤នាក់ផងដែល លោកឡឺរេស៊ីដង់តាកែវ ចាត់ឲ្យជូនដំណើរទៅនឹងអ្នកចែវ៤នាក់ព្រម ទាំងចិនម្ចាស់ទូកម្នាក់ទៀតជា ១៣ នាក់ ក៏បានចេញដំណើរទៅពីតាកែវ ដោយទូកនោះក្នុងវេលាម៉ោង ១០ យប់ថ្ងៃនោះឯង ដោយហេតុយប់ ងងឹតណាស់ពិបាកនឹងមើលឲ្យឃើញផ្លូវឆ្ងាយ ងាយនឹងចែវទូកទៅ ឲ្យបានស្រួល ព្រោះទីវាលបឹងសឹងតែដុះដេរដាសដោយត្រកៀត ត្រ-កួន ព្រលិត កំពឹស ព្ទួយ កណ្ដាក ក្រែង ស្រងែ ក្រចាប់ គាន់ គាប់ ពាស ពេញបឹង ឯអ្នកចែវទូកក៏ចេះតែចាំប្រឹងចែវផងដោលផងពុំមានឈប់

ដោយពួកថៃសុទ្ធតែប្រសប់ ហើយស្គាល់ផ្លូវច្បាស់ច្រើនស្រុកគេ ណាស់ក៏បានទៅដល់ក្បាលពោធិ៍ នៅវេលាម៉ោង ២ រំលងអធ្រាត្រ យើងខ្ញុំទាំងអស់គ្នាក៏ជ្រៀតជ្រែកបកខ្លួនប្រេបផ្ទះក្នុងសុបិនស្រា ហើយ នាំគ្នាចូលទាន់ដំណេកនៅទីនោះ ។

លុះព្រឹកព្រាងស្វាងព្រះសុរិយារះណាវ៉ែយ ពេលម៉ោង ៨ ថ្ងៃ ៥ សេបតមប្រើក៏ចេញចូលពីក្បាលពោធិ៍តាមផ្លែកទៅបូជុក (ទាក់ផ្ចុក) ដល់ម៉ោង ១១ ព្រឹកឈប់សម្រាកចូលទានបាយនៅកណ្ដាលបឹងទាង នាយគ្មិនព្រៃផ្កាថ្កិច រួចហើយក៏ចេញចូលះតបពីព្រៃកវែកស្រែផែទឹង ស្ដើងដំរង់សំដៅទៅលើភ្នំបុរីទិភបានខ្យល់ហោកសង្ខារគ្រើបធ្លាប់ដល់ភ្នំជា ។ ! គួរឲ្យអស្ចារ្យពន់ពេក ដោយក្រឡេកមើលទៅលើរបឹងសន្ទឹងផែធ្លាយធំ ទូលាយដាប់អន្ទុយភ្នែក ឃើញតែទួលភូមិទីកំពង់ដែលនៅធ្លាយជាអនេក ឯណោះ១ ឯណោះ ១ ដូចជាកោះនៅកន្លែងកណ្ដាលសមុទ្រធំ ពួកអាក សត្វជំយក្សដៃព្រៃភ្នំ បើមានឈើណាមួយដុះផែងឯងផុតពីទឹក ពួកសត្វកខាត់សត្វប្រកែ កុក ក្រសារ ចង្រៀលខ្យង ត្រយង កុកក្រក ហើរត្រៀលធ្លាត់ប្រជុំគ្នាទំណែនណាន់គាន់គាប់ មានទាំងសត្វស្មោញ ហាលស្លាបសម្រាកកំឡាំង ហើយក៏តាំងហើរទៅរកមុជចាប់ត្រីជាចំណី ទៀត ចំណែកមនុស្សអ្នកស្រុកឃើញតែអុំទូកព្រោងព្រាតពីភូមិ ១ ទៅ ភូមិ ១ ខ្លះទៅរកកាត់ស្មៅឲ្យគោស៊ី មានទូកខ្លះទៀតដាក់បង្កក-ស្មៅ

គេចាប់ខ្សែដកព្រលិត បើប្រទះទីងសត្វកណ្ដាប់ប្រែងប្ដូរពស់រែកស្រងែ នៅដិតគេក៏ចាក់-ពួយដោយស្ទូ-ប្ដូរប្រកស់ម្ចាប់ហើយកាត់ក្បាលពន្ទាត់សែស្រគ ហេតុនោះហើយបានជាកន្ទុំមួយៗ ដែលអុំមកជិតឃើញតែសាច់ពស់, កណ្ដារប្រែង, ខ្សង, ព្រលិត ឱ! ពុទ្ធោអើយ? គួរឲ្យអាណិតសត្វទាំងនោះណាស់ ដូចសត្វខ្សងទំប្រែងបណ្ដែតប្រាណព្រោងព្រោតក្នុងទឹកបឹង បញ្ចេញខ្លួននៅស្ងប់ប្រែងជញ្ជក់អ័លទឹងកំអែលដែលជាប់នៅទីងសៅមើលទៅហាក់ដូចជាគ្មានទុក្ខព្រួយអ្វីសោះ តែមិនដូច្នោះមនុស្សគេចាប់ដាក់ទូកយកទៅស្ងោរដោយទឹកក្ដៅគួរឲ្យអនិច្ចា ៗ ល ៗ

លុះដល់សៀលព្រះសុរិយា ម៉ោងពីរកន្លះថ្ងៃ ៥ សេបតមប្រើក៏បានដល់ទៅកម្ពុជា យើងខ្ញុំក៏ចូលចតទូកនៅជើងកំផ្ទែងផ្លូវដែលឡើងទៅវត្តយួន ( ដូចាប់សឹង ) ដែលធ្វើជាប់នឹងគុហាពី ១ នៅជើងភ្នំខាងជើង ៦ ខ្លួនខ្ញុំនឹងលោកអ៊ុក-សែន បានឡើងពីទូកហើយចូលទៅក្នុងវត្តយួនទាំងពួ នៅកម្ពុជាដែលមានព្រះពុទ្ធរូបត្រយកក្នុងពេលនោះ បាននិយាយប្រាប់លោកយួននឹងជាតិចេនជាម្ចាស់វត្តទាំង ៣ នោះថា យើងដែលមកនេះគឺកជុតាត្រូវក្រសួងពុទ្ធសាសនបណ្ឌិត្យភ្នំពេញ ប្រើឲ្យមកជីកនាំយកព្រះពុទ្ធរូបក្នុងវត្តទាំង ៣ ទៅដាក់តុកមោសារមន្ទីរខេត្តក្រុងភ្នំពេញ រឿងនេះប្រហែលជាលោកស្ហ៊ុបបុស្តិ៍ទីងលោកមេឃុំបានជំរាបឲ្យដឹងពីថ្ងៃមុនហើយដែរឬ?

ចំណែកយួនទាំងអម្បាលម៉ាន លុះបានឮខ្ញុំនិយាយយ៉ាងនេះទៅ ហើយក៏ប្ដូរទឹកមុខគ្រប់គ្នា ឯពួកស្រី ៗ ប្រែកតែចេញទឹកភ្នែករលីង ពោងនិយាយរអាក់រអួលថា ព្រោះអាល័យស្ដាយព្រះពុទ្ធរូប លើកដៃសំពះហើយនិយាយថា យើងបានដឹងគ្រប់គ្នាហើយ ប៉ុន្តែយើងសុំអង្វរចៅសុំឲ្យបង្អង់ចាំ ២ ថ្ងៃសិន ព្រោះបានជាឲ្យដំណឹងទៅប្រាប់បងប្អូនដែលនៅឆ្ងាយ ៗ រហូតដល់ចូដុក. បានយើ, ភ្នំបូរ៉, តាកែវ ។ល។ ដែលទៅហើយថាថ្ងៃ ៧ សេចគមប្រែ ក្រោយនេះនឹងឲ្យមកជួបជុំគ្នាធ្វើបុណ្យនមស្សការជូនដំណើរព្រះពុទ្ធរូប ដែលនឹងឃ្លាតចាកចោលស្ថាន ជាកិច្ចដ៏សមគួរដល់សេចក្ដីកប់កានរបស់យើងដែលធ្លាប់គោរពប្រណិប័តន៍ព្រះអង្គមកជាយូរអង្វែងហើយ បើកជការមកយកទៅហើយ យើងក៏ពុំហ៊ានកំហឹង តាមសំដីពួកយួនដែលចេះនិរនោះគួរឲ្យអាណិតណាស់ ព្រោះនិយាយផងយំទឹកភ្នែកផង ដោយជាតិយួនជាអ្នកប្រសប់ខាងធ្វើឲ្យអាណិត ប៉ុន្តែខ្លួនខ្ញុំគិតឃើញថា បើទទួលអង្វរតាមពាក្យយួនសុំ មុខជាយឺតមិនទាន់ដល់ពេលប្រជុំធ្វើបុណ្យនៅឃុំអង្គបុរី ថ្ងៃ ១២ សេចកម្រប់នោះទេ ព្រោះពិចិត្យមើលទៅព្រះពុទ្ធរូប ១ អង្គ ៗ មិនងាយនឹងយកទៅដាក់ទូកបានដោយឆាប់ឡើយ ម្ល៉ោះហើយខ្ញុំក៏ប្រាប់តបទៅពួកយួនវិញថា ខ្ញុំទទួលអង្វរបងប្អូនយួនទាំងស្រុងគ្នាមិនបានទេ ព្រោះជាហេតុនាំឲ្យយឺតយូរមិនទាន់ពេលបុណ្យថ្ងៃ ១២ នាំឲ្យទៅហួសយុរាយ

ខ្ញុំស្ដាប់ឆ្ងាស បើអ្នកទាំងអស់បានសេចក្ដីអនុញ្ញាតយល់ព្រមពីលោកឡឺប្រេស៊ីដង់ ទីងហៅហ្វាយខែត្រាកែមក ទើបខ្ញុំទទួលព្រមបានវេលាព្រឹកស្អែកថ្ងៃ៦សេបតម្ប៍ ខ្ញុំនឹងប្រមូលពួកគូលីមកឲ្យនិមន្តព្រះពុទ្ធរូបទៅដាក់ទុកជាមិនខាន ។ តពីនេះទៅខ្ញុំបាននិយាយពន្យល់ពួកយួនទាំងនោះទៀតថា កិច្ចការដែលត្រូវការយករូបទាំងប៉ុន្មាននោះពុំមែនយករូបដែលអ្នកទាំងអស់គ្នាធ្វើខាងក្រោយនោះទេ កិច្ចការត្រូវការយកតែរូបណាដែលជារបស់ខ្មែរពីបុរាណប៉ុណ្ណោះ ឯព្រះពុទ្ធរូបរបស់អ្នកទាំងអស់គ្នាដែលកិច្ចការបំរុងនឹងយកក្នុងពេលនេះ ព្រោះតែអ្នកទាំងអស់គ្នាយករូបរបស់ខ្មែរពីបុរាណមកប៉ះស៊ីម៉ង់តែកែប្រែធ្វើជាព្រះពុទ្ធរូបឡើង ដោយបំណងថានឹងជួសជុលរូបនោះរក្សាទុកឲ្យបានគង់ល្អតទៅ ឬក៏ដោយចេតនាដូចម្ដេចរបស់អស់អ្នកក្នុងពេលដែលធ្វើនោះ តែតាមយោបល់ផ្លូវកិច្ចការក្រសួងរក្សាបុរាណវត្ថុវិញយល់ថាការធ្វើបែបនេះមិនឲ្យឈ្មោះថាស្រឡាញ់–រក្សាបុរាណវត្ថុ ដោយល្អបានទេ ដោយពិតនោះបើឃើញមានបុរាណវត្ថុនៅក្នុងទីណាមិនត្រូវទៅគាស់កកាយយកអ្វី បើជារូបឬក្បាច់មិនត្រូវវាយបំបែកបំបាក់តាមបំណងចិត្ត ឬដែលបាក់បែកហើយមិនត្រូវយកទៅប៉ះជួសជុលបូកស៊ីម៉ង់តបំពេញធ្វើឲ្យប្លែកពីភាពដើមឡើយ សូម្បីធ្វើដោយចិត្តជ្រះថ្លាប្រាថ្នាបុណ្យកុសលយកមាសទៅបិទលាបឲ្យល្អឡើងក៏ពុំគួរដែរ បើធ្វើតាមទំនងដូច

និយាយខាងលើនេះ ទើបបានឈ្មោះថាបេះស្រឡាញ់-ក្រោបុកណាវត្ត ដោយល្អបានសេចក្ដីសរសើរមកពីក្រសួងក្រោបុកណាវត្តផង វេលាដែល ពលការត្រូវការយកទៅយើងក៏ពុំមានសេចក្ដីសោកស្ដាយប៉ុន្មានផង ដែល ខ្ញុំនិយាយដូច្នេះមកពីខ្ញុំបានដើរមើលបុកណាវត្តដោយខ្លួនខ្ញុំបានសង្កេត ទៅយល់ច្បាស់ណាចនឹងហើយបានថា បុកណាវត្តក្នុងស្រុកខ្មែរចាំងមូលដែល វិនាសទៅដោយកុសលចេតនារបស់អ្នកស្រុក: ស្ទើរតែទាំងអស់ គឺដោយ ហេតុទៅគាស់រំលាយទីបុកណាវត្តចោលហើយកសាងវត្តអាកាសសង្កត់ ពីលើ ឬក៏ទៅដឹកគាស់កកាយយកថ្ម-ចុះផ្កាយកទៅធ្វើជាខឿន វិហារនិងជណ្ដើរជាដើមក្នុងទីធងនៃដោយប្រាថ្នាយកបុណ្យពីការសាងថ្មី ឯសេចក្ដីដែលធ្វើឲ្យវិនាសគ្រឿងដំណែលរបស់បុព្វបុរសមិនគិតផងសោះ ដូចពាក្យបុរាណថា "បានថ្មីចោលចាស់ពុំទីកនា" រឿងនេះយើងជាពុទ្ធ-សាសនិកជនគួរគាត់សេចក្ដីថាដូចម្ដេចៗ រួចហើយខ្ញុំនឹងលោកអ៊ុក-សេន ក៏លាពួកយួនត្រឡប់ទៅកន្លែងទូកវិញ បានជញ្ជូនឈើទាំងគ្រឿងផែក ចេញពីទូកដាក់លើគោកជាស្រេច ដល់ម៉ោង ៦ ល្ងាចខ្ញុំតែម្នាក់ឯងរក ជួលទូក ១ ជិះទៅអង្គរបុរី ដល់ហើយក៏ប្រាប់មេឃុំនឹងសេហ្មប៉ុស្ដិ៍ឲ្យរក គូលីឲ្យ ៣០ នាក់ ឯមេឃុំក៏បានបាត់មនុស្សឲ្យទៅកេណ្ឌបណ្ដាស្រុក ដែលនៅក្នុងភូមិព្រែកដាជិតភ្នំដាទឹងភ្នំបាទេព បំរុងទឹងឲ្យទៅធ្វើការជា មួយនឹងខ្ញុំបានចំនួន ៣០ នាក់ពីល្ងាចថ្ងៃ ៥ សេបតម្ប៊ែទុកជាស្រេច ៗ

## (អំពីយកព្រះនារាយណ៍ ភ្នំដា)

ថ្ងៃ ៦ សេបតិមប្រិ៍ ម៉ោង ១០ ព្រឹក ពួកគូលីមកគគិកជួបជុំគ្នា ឯពួកខ្ញុំក៏បានទទួលទានអាហាររួចជាស្រេច ឯពួកយួនអ្នកស្រុកសឹងតែបានយកស្គរគងឃោះ ទៅនៅប្រចាំគោះជួយហៃហាមផងព្រមគ្នាទាំងអស់តែម្នង ចូលទៅកន្លែងវិហារគ្រព្រះនារាយណ៍ តាមពាក្យយួនទាំងឡាយហៅជាជួរក្នុងផែយឿង ហើយក៏តាំងប្រណាម្យដៃទាំងអស់គ្នាឡើងចំពោះព្រះនារាយណ៍ និយាយសុំខមាទោសថា យើងខ្ញុំទាំងឡាយមកអញ្ជើញព្រះនារាយណ៍ សូមឲ្យបានសុខសប្បាយទាំងអស់គ្នា អាក្សេក្រុតិវេទពាក្យអ្នកតាសូមកុំប្រកាន់ទោសា ព្រោះយើងខ្ញុំទាំងអស់គ្នាដែលមកនេះពុំមែនដោយចិត្តក្នុងប្រមាទពាធាញ្ញាញឲ្យអន្តរាយ តំណើតាមបង្គាប់នាយទៅហ្វាយម្ចាស់ផែនដី សូមអញ្ជើញព្រះនារាយណ៍និមន្តដោយមេត្រីសោះព្រមទាំងកំណាត់រូបធំ-តូចទាំងអស់ ទៅសណ្ឋិតនៅសារមន្ទីរភ្នំពេញ ។ រួចហើយទើបឲ្យពួកគូលីយកពូថៅរំព្រះនារាយណ៍សែងរំកិលចុះពីលើចល្អង មានទាំងស្គរគងឃោះគោះតាំងភ្លយដំគត្រែកតត្រែងពីខាងមុខ ឯព្រះនារាយណ៍ក៏អញ្ជើញទៅតាមគជាសុខសប្បាយ ដល់បដល់ទុកកន្លែងទូកហើយជាស្រេច ទើបគេត្រឡប់ទៅប្រមូលយកកំណាត់រូបផ្សេងទៀតមានចំនួនទាំងអស់ដូចតទៅនេះ គឺ :

រូបព្រះនារាយណ៍ឈរដៃបួន ១, កំណាត់ខ្លួន ៤, កំណាត់ជើងនិងកំណាត់ផ្សេងទៀត ៨-រួមទាំងអស់ជា ១៣ ។

ឯព្រះនារាយណ៍ជាទីគោរពគប់អានបំផុតរបស់យួនទាំងខ្មែរ គេទុកថាជាព្រះឮកែសម្រាប់បន់ស្រន់ក្នុងការអាសន្នគ្រប់ប្រការ បើបានសម្រេចដូចប្រាថ្នា ទាំងថ្វាយអង្ករ, ស្លាធម៌ដូង, ភ្លេងសៀម, ឬនិមន្តភិក្ខុសង្ឃជារថ្វាយ, ធ្វើបុណ្យផ្កាថ្វាយ, ធ្វើកឋិនថ្វាយជាដើម ហេតុនោះបានជាលោកគ្រូ អ៊ុងដាំង អាយុ ៦៨ ឆ្នាំជាមេវត្តទាំងយាយជីម្នាក់ឈ្មោះ បាកូ អាយុ ៧៥ ឆ្នាំដែលជាអ្នកនៅរក្សាវត្តនោះជាទូ តែងបានកែរចិញ្ចឹមជីវិតទាំងរក្សាវត្តដោយសារដង្វាយដែលកើតអំពីអានុភាពរបស់ព្រះនារាយណ៍នោះឯង ។

ព្រះនារាយណ៍នេះ កាលពីដើមរវាង ៤០ ប្លាយឆ្នាំហើយ មានយាយចាស់ជាតិយួនម្នាក់បានធ្វើវិហារប្រក់ក្បឿង ១ ថ្វាយ ដោយជឿជាក់ថា ព្រះនារាយណ៍នោះឲ្យអំណោយផលស័ក្តិសិទ្ធិជាទីអស្ចារ្យដល់ខ្លួន ដល់ខាងក្រោយមក អំណោះគេអំពីយាយនោះទៅ វិហារក៏ដល់ទ្រុឌការបាក់បែកអស់ទៅព្រោះគ្មានគេថែរក្សា ទើបតែក្នុងរវាង ៨ - ៩ ឆ្នាំកន្លងមកនេះ ទើបមានពួកយួនមកធ្វើវិហារប្រក់ស្លឹក ១ ថ្វាយ ឯរូបព្រះនារាយណ៍ដែលបាក់បែកនោះបានបូកប៉ះភ្ជាប់ដៃជើងទាំងក្បាលធ្វើជារូបឈរមានដៃ ៤ តាមទំនងដើមតែកែប្រែជារបៀបបែបរូបខាងយួន - ចិនវិញ សម្រាប់មានអាសន្នចូលទៅបន់ស្រន់ម្ដងៗ ប៉ុន្តែការដែលបន់នោះទុកជាសម្រេចក្ដីមិនសម្រេចក្ដី ក៏គេត្រូវតែលាបំណន់ថ្វាយដង្វាយតាម

ពាក្យដែលគេបន់នោះជាធម្មតា ឯព្រះនារាយណ៍នេះពូកែឬមិនពូកែពុំប្រាកដ ប៉ុន្តែគ្រាន់ដែលអ្នកស្រុកចុះចូលគប់អានឃើញពិតជាច្រើនមែន ព្រោះវេលាដែលយកព្រះនារាយណ៍ទៅដល់អគ្គីបុរីចតទូកទុកនៅមុខវត្តកំពង់ហ្លួងកន្ទ ១ ថ្ងៃ ឃើញមានខ្មែរចិនយួនជាច្រើន ចូលទៅលាបំណន់ដែលបានបន់ទុកយូរហើយ ដោយថ្វាយអង្ករខ្លះ ស្លាធម៌ជូនខ្លះ ភ្លេងសៀមខ្លះ ឬគ្រាន់តែអុជធូបទៀនថ្វាយនោះក៏មានច្រើនជាអនេក ឯព្រះពុទ្ធរូបមែននោះ ឃើញច្រើនតែអុជធូបទៀនថ្វាយបន្តិចជាធម្មតាប៉ុណ្ណោះ ឯព្រះនារាយណ៍នោះសូម្បីកាលចេញទូកពីអគ្គីបុរីទៅចូដុក (មាត់ជ្រូក) ពីចូដុកមកដល់ភ្នំពេញ លោកអ៊ុក-សេន និងសៅ-សឿង ដែលនៅក្បែរទូកបាននិយាយប្រាប់ខ្ញុំថា មានចិន-យួនចូលទៅថ្វាយបង្គំបន់ស្រន់និងថ្វាយធូបទៀនស្លាធម៌ជូនជាដរាប មានទាំងថ្វាយប្រាក់ ១,០០ ឬ ៥០ សេន ២០ សេនជាច្រើនគ្នាផង ប៉ុន្តែការថ្វាយដោយប្រាក់ច្រើន តែមិនទទួលឲ្យវិញជាធូបទៀនថ្វាយវិញ លុះមកដល់ភ្នំពេញដាក់ទុកក្នុងសារមន្ទីរហើយ ក៏នៅតែមានជាតិយួនចូលទៅគោរពប្រណិប័តន៍ជាហូរហែទៀត ដោយហេតុពិតយ៉ាងនេះហើយ បានជាលោកគ្រូ អ៊ុនផាន់ នៅវត្តព្រះនារាយណ៍ (ជួអ៊ុនដៃយឿង) និងជាតិយួនខ្មែរសោកស្ដាយរូបនេះណាស់ ទុកជាធ្វើសង់វិញក៏មិនពេញចិត្តស្មោះអស់ពីពោះដូចជារូបមុនដែរ ។

# អំពីយកព្រះពុទ្ធរូបក្នុងគុហាទី ១ (ភ្នំដា)

លុះយករូបក្នុងវត្តព្រះធាតុបេណ៍រួចជាស្រេច ក្នុងវេលាម៉ោង ៣ រសៀលហើយ ដោយនៅពេលវេលាច្រើន យើងខ្ញុំក៏នាំគ្នាចូលទៅយកព្រះពុទ្ធរូបក្នុងគុហាទី ១ យួនហៅថា ជួចាប់សឹង ជាវត្តយួន ១ មានតែលោកយួន ១ រូបឈ្មោះឈឹង អាយុ ៥០ ឆ្នាំ យួនហៅថាអុងជូ ទីង យាយជីម្នាក់ឈ្មោះបាខា អាយុ ៦០ ឆ្នាំនៅចាំរក្សាតទៅទៀត ចំណែកឯយាយបាខា លុះបានឃើញយើងខ្ញុំចូលទៅប្រាប់ថាមកយកព្រះពុទ្ធរូបកាលណា ក៏អាក់មុខចេញពុំមានចរចា មានតែត្រាស្រក់សស្រោកយំត្រូកត្រោកសោកស្ដាយព្រះពុទ្ធរូបដែលប្រាសចេញពីកន្លែង។ ទុកជាខ្ញុំថ្លែងប្រាប់ថានាយទៅហ្វាយខ្ញុំនឹងធ្វើសងវិញក៏នៅតែមិនបាត់ស្ដាយ បាយាយតបមកវិញថា មិនពេញចិត្តស្មោះអស់ពីពោះពុងដូចគង្គពុទ្ធរូបដែលធ្លាប់ប្រណិប័តន៍មកហើយទេ រួចហើយយើងខ្ញុំនឹងពួកគូលីចូលទៅក្នុងគុហា ខមសក្ការបង្វាយបង្គំសុំខមាទោសដូចមុន ហើយក៏យកដែកជំនីកទៅគាស់ទ្រុះបល្ល័ង្កទំមន្តព្រះពុទ្ធរូបដង្ហែចេញមកពីគុហា មានស្ទួឈ្មោះ វាយដំគគ្រិកគគ្រេងឯកបដល់ដំកល់ទុកក្នុងទូកហើយជាស្រេចក្នុងវេលាម៉ោង ៤ កន្លះល្ងាចថ្ងៃ ៦ សេបតំប្រ៍ ។

ព្រះពុទ្ធរូបនេះឯង កាលដែលពួកយួនចូកប៉ះរូបចាស់ពីបុរាណជារូបឈើ តែធ្វើជាព្រះពុទ្ធរូបទន់ភ្លន់តាមរបៀបយួនទៀតនោះ ឃើញ

ជាមានគំនិតល្អណាស់ បេះរកក្រពុំអស់ទាំងកំណាត់ដៃជើងដែលបែក ចាក់ទៅសល់ប៉ុន្មានឲ្យគង់នៅ ដោយយកកំណាត់បុង្គជើងទៅទ្រាប់ធ្វើជា បល្ល័ង្កទ្រខ្នងខាងមុខ · កំណាត់បុងដៃញាត់ចុកពីខាងក្រោមខ្នង ឯ កំណាត់ខ្លះទៀតគេផ្គុំផ្គួបសំរាប់អមពោះទាំងសងខាង សំអាងជាព្រះ-ហស្តដ៏ក្រៃលែងគ្នាគួរឲ្យសរសើរថាជាអ្នកចេះរកក្រុះដោយល្អបាន ។

លុះដល់ម៉ោង ៦ កន្លះល្ងាចថ្ងៃនោះឯង ទើបឃើញពួកយុទ្ធជនចំនួន ៤ នាក់ជាវិស្វកម្មក្រសួងសាធារណការតាំងតែពីទូកទៅដល់ក៏ជាជួបនឹង យើងខ្ញុំទាំងអស់គ្នា ហើយបែកសំបុត្រ ១ ច្បាប់ដែលលោកឡឺរ៉េស៊ីដង់ ទ.ង ព្រះបាទម្ចាស់ទៅហ្វាយខែត្រតាកែវ ផ្ញើទៅលោកឌេយ៉ុំទីងឡាំក សេហ៊ុំបុំស្តិ៍ សេចក្ដីថា... លោកវិស្វករមិនបានមកទេ ព្រោះមានសំបុត្រ ខែវ្រលួសពីព្រែនតរផ្ញើមកថាម្ដាយលោកអនិច្ចធម្ម សុំឲ្យតែពួកវិស្វកម្ម ទាំង ៤ នាក់នេះមកជំនួស ព្រោះជាអ្នកចេះការស្ទាត់ប្រាកដដូចជាលោក វិស្វករដែរ ៗ លុះ ៗ យើងខ្ញុំមានសេចក្ដីត្រេកអរឥតឧបមា ដោយបានឃើញ ពួកវិស្វកម្មក្រសួងសាធារណការទៅដល់ ព្រោះកាលមុនខ្វល់ចិត្តជ្រុល មិនធ្លាប់ធ្វើការផ្ទួន ឯជីយួនទាំងអស់ក៏សុទ្ធតែមានចិត្តសប្បុរសរួសរាក់ ដោយពុំហាមិនធ្វើដៃចាំហាសញ្ញាដាក់ពួកយើងខ្ញុំឡើយ ... ហើយ វេលាបរិភោគបាយ ប្រញាប់យកគ្នាលូកប្រប៉ូកប្រថល់ទៅមកតាមត្រូវការ សប្បាយត្រប់ត្រាក្នុងវេលានោះហោង ។ (មានត)

## រឿងដំណើររបស់លោកធុតង្គ ជាតិចិន ១រូប

### ឈ្មោះហួន-ឆាង

### ពាក្យផ្ដើម.

ក្នុងការប្រែសេចក្ដីរឿងដំណើរមួយជាភាសាបារាំង ដែលលោកអ្នកប្រាជ្ញធំៗ នៅសាកលបារាំងសេសចុងបូព៌ាប្រទេស បានតែងឬរៀបរៀងឡើងនោះ ជាភារៈយ៉ាងធ្ងន់ល័អ្នកប្រែ ដែលមានចំណេះចេះដឹងតិចក្នុងវិជ្ជាភាសានេះ ដែលជាភាសាក្រប៉ផុតមួយក្នុងលោក ។ ហេតុនេះអ្នកប្រែរឿងនេះមកជាខេមរភាសា សូមបញ្ជាក់ដល់អ្នកមើលទាំងឡាយថា អ្នកប្រែមិនមែនជាអ្នកមានចំណេះចេះដឹងជ្រៅជ្រះ ក្នុងវិជ្ជាភាសាបា-រាំងសែសទេ ការប្រែរបស់យើងគង់មានភ្លាំងភ្លាត់ខ្លះជាពុំខាន តែយើងមានសង្ឃឹមថា គង់បានទទួលអភ័យទោសអំពីសំណាក់អ្នកមើលឲ្យទៅ ។

បំណងធំរបស់យើងក្រៅពេញចង់ឲ្យបណ្ដាញាតិជាតិខ្មែរផងគ្នា ដែលមិនបានចេះភាសាបារាំងសោះនោះ បានដឹងរឿងដំណើរប្លែកៗ របស់នានាប្រទេសខ្លះ ដើម្បីជាគ្រឿងប្រដាប់វត្ថុបញ្ចូនចំណេះចេះដឹងទៅប៉ុណ្ណោះ ។

មួយវិញទៀត រឿងដំណើររបស់លោកធុតង្គជាតិចិនឈ្មោះហួន-ឆាងនេះគួរទុកជាគោលឯកសារមួយរបស់ភូមិសាស្ត្រ និងប្រវត្តិសាស្ត្រប៉ែកខាងពុទ្ធសាសនាបានខ្លះ ក្នុងរវាងសម័យមួយពាន់ឆ្នាំកន្លងមកហើយ ព្រោះ

ៃរឿងរ៉ាវទាំងនោះ ជាគ្រឿងជួយបំភ្លឺឲ្យឃើញសេចក្ដីចំរើនរុងរឿងនៃព្រះពុទ្ធសាសនា ដែលតាំងនៅក្នុងភាគផែនដីផ្សេងៗ ក្នុងប្រទេសឥណ្ឌា ក្នុងប្រទេសចិន និងក្នុងប្រទេសនានានៅទ្វីបអាស៊ីកណ្ដាល ក្នុងសម័យព្រេងនាយនោះផង ។ ក្រៅអំពីនេះរឿងរ៉ាវដែលលោកហ្វូន-ឆាងបានកត់ត្រាទុកមកតាំងអំពីកាលនោះ រមែងមានប្រយោជន៍ជាសំខាន់ ដល់ភូមិសាស្ត្រនិងប្រវត្តិសាស្ត្រ សម្រាប់ស្រុកទេសដោយឡែកទៀតផង ។

ហេតុដូច្នេះ ការប្រែរឿងនេះមកជាខេមរភាសា គង់មានប្រយោជន៍ដល់ពួកពុទ្ធសាសនិកជនជាខេមរជាតិយើងខ្លះជាពុំខាន ព្រោះតាមសេចក្ដីផ្លូវរឿងនោះ បានបង្ហាញបំភ្លឺឲ្យយើងបានឃើញសេចក្ដីជ្រះថ្លាយ៉ាងមុតមាំណាស់និងសេចក្ដីព្យាយាមយ៉ាងសំបើមអស្ចារ្យ របស់ពុទ្ធសាស-និកបព្វជិតជាតិចិន ១ រូប ដែលបានធ្វើដំណើរដើរធុតង្គទៅកាន់បូជនីយ-ដ្ឋាននានារបស់ពុទ្ធសាសនា ក្នុងប្រទេសឥណ្ឌាសម័យបុរាណ ។ សម័យនោះហើយ ដែលមានផ្លូវគមនាគមលំបាកជាបំផុត ព្រោះត្រូវតែដើរកាត់ឡើងផងភ្នំព្រៃដ៏ដេរដាសទៅដោយហិមៈ មានកំពូលខ្ពស់ត្រ-ដែតជាប់ពពក គ្មានប្រឡាយទឹកហូរធ្លាក់ពីលើភ្នំចុះមក ឬ ឬគេគុកគគាក់ផតស្រោក មានអាកាសសើមត្រជាក់ដូចជាទឹកកកហើយផ្លូវឥតលត្រូវ

ដើរកាត់ចូលព្រៃព្រឹក្សាដ៏ធំដេន គួរឲ្យស្ញែងខ្លាចក្រែងអន្តរាយដល់ជីវិត អំពីសត្វសាហាវយង់ឃ្នងនានា ជួនកាលត្រូវដើរចូលសមុទ្រខ្សាច់ធំសំ-បើមល្វឹងល្វើយ មើលទៅឃើញតែដើមមេឃនៅឆ្ងាយលប់លិច ឥតមានឃើញរុក្ខជាតិ១ដើមឬស្មៅ១គុម្ពសោះ ហើយមានអាកាសក្ដៅហែងស្ទើរតែគេងរលាយ ទាល់តែព្រះអាទិត្យរៀងរេចអស្ដង្គតទៅ ទើបសម្រាលកំដៅខ្សាច់ឲ្យបានត្រជាក់បន្តិចឡើងៗ លុះដល់យប់សន្ធ្យាទើបគេអាចធ្វើដំណើរដើរចូលកាត់ទៅពីតំបន់មួយទៅតំបន់មួយបាន ហើយនៅតាមកេន្ទផ្លូវទាំងនោះសោតទៀត សឹងប្រទះឃើញតែឆ្អឹងសរដេរដាស គឺសុទ្ធតែជាឆ្អឹងខ្មោចមនុស្សឬសត្វ ដែលដល់នូវមរណៈតាមរយៈផ្លូវដាច់ស្រយាលនោះ ដោយហេតុវិបត្តិអន្តរាយផ្សេងៗ សឹងមានច្រើនជាអនេកណាស់ ។

ហេតុដូច្នេះ ទើបគួរឲ្យស្ងើច, គួរឲ្យស្ញប់ស្ញែងជាពន្លឹក ចំពោះការធ្វើដំណើរដើរឆ្លងកាត់ផ្លូវឆ្ងាយដាច់ស្រយាល របស់លោកធុតង្គ ហួន-ឆាង ដូចយើងបានពណ៌នាមកនេះ ។ យើងយល់ថា លោក ហួន-ឆាងនេះគួរទុកដាក់ជាមនុស្សម្នាក់ ដែលគ្រប់ដោយលក្ខណៈ របស់មហាបុរសៈច្រើនប្រការគឺ មានបញ្ញាស្មារតីខ្ជាប់ខ្ជួន, មានព្យា-យាមធំ, មានសេចក្ដីក្លាហានអង់អាចមិនខ្លាចស្លាប់ មានសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនាយ៉ាងមាំមួនជាបំផុត... ។ មនុស្សបែបនេះ ទើបអាចធ្វើ

ការធំៗបានសម្រេច ទុកជាកេរ្តិ៍តកដល់ជនជាន់ក្រោយតៗមកជាច្រើនសតវត្សរ៍ មនុស្សបែបនេះហើយដែលគេបានកត់ត្រាឈ្មោះ ទីងរឿងរ៉ាវរបស់លោកទុកក្នុងពង្សាវតាររបស់សាសនាឬរបស់ជាតិ អស់កាលដ៏លង់អន្លង់វែងឆ្ងាយជាប្រាកដ ។

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

---

# រឿងរ៉ាវរបស់លោកធុតង្គជាតិចិន ១ រូប

## ឈ្មោះ ហួន-ឆាង.

ហ្លួងនិពន្ធមន្ត្រីញ៉ុក-ថែម ស្រង់និងប្រែចេញអំពីសៀវភៅ, Religieux et Pèlerins en Terre d'Asie របស់លោក Victor Golaubew សមាជិកសាលាបារាំងសែសនៅចុងបូព៌ា-ប្រទេស ។

— ១ —

កាលពីឆ្នាំ ៦១ នៃគ្រិស្តសករាជនោះ, ព្រះចៅកជាធិរាជព្រះនាម មិង-ទី ជាតិចិន ទ្រង់ព្រះសុបិនឃើញព្រះ ១ ព្រះអង្គដែលទ្រង់មិនដែលស្គាល់សោះ ព្រះកាយរបស់ព្រះអង្គនោះមានរស្មីភ្លឺ ដូចជាមាសយ៉ាងបរិសុទ្ធ ហើយអណ្តែតទៅតាមអាកាសបាន ដូចជាពួកទេវមនុស្ស ព្រះបាទមិនប៉ះពាល់ដល់ដីឡើយ ។ លុះដល់ព្រឹកឡើង ទ្រង់

តើនចាកពីព្រះក្រឡាបន្ទំ ទើបទ្រង់សាកសួរពួកមន្ត្រីទីប្រឹក្សារបស់ព្រះអង្គ អំពីសុបិននិមិត្តនោះ ៗ មានក្រុមប្រឹក្សាម្នាក់ក្រាបបង្គំទូលព្រះអង្គថា :

“ព្រះករុណាថ្លៃវិសេស ទូលព្រះបង្គំជាខ្ញុំម្ចាស់ដឹងមកថា នៅប្រទេសឥណ្ឌាមានមនុស្សម្នាក់គេហៅថា ព្រះពុទ្ធ ៗ មនុស្សនោះបានសម្រេចជា “គៅ” គឺប្រាជ្ញាត្រាស់ដឹងដ៏ខ្ពង់ខ្ពស់ ៗ ព្រះកាយរបស់ព្រះអង្គនោះស្រាលណាស់ អាចអណ្តែតទៅតាមអាកាសបាន ៗ សូមទ្រង់ព្រះមេត្តាប្រោស, ប្រហែលជាព្រះអង្គនោះហើយទេដឹង ដែលទ្រង់បានទតឃើញក្នុងព្រះសុបិន?

ទើបព្រះចៅរាជាធិរាជ ទ្រង់ចាត់បញ្ជូនរាជទូត ១ ក្រុមទៅប្រទេសឥណ្ឌាក្នុងខណៈនោះឯង ៗ លុះកន្លងទៅជាច្រើនឆ្នាំ ទើបក្រុមរាជទូតនោះត្រឡប់មកដល់ស្រុកចិនវិញ ព្រមទាំងបាននាំយកភិក្ខុពីររូបដែលចេះស្ទាត់ក្នុងគម្ពីរសំស្ក្រឹតហើយមានទាំងសេះស ១ សម្រាប់ផ្ទុកគម្ពីរដីកាពីខាងលិចផង ព្រមទាំងព្រះរូបឆ្លាក់ពីឈើខ្លឹមច័ន្ទន៍និងគំនូរទាំងឡាយ ៗ មានគំនូរមួយនោះ ជាគំនូរព្រះពុទ្ធសាក្យមុនី គេបានលាត្រដាងគំនូរនេះថ្វាយចំពោះព្រះភក្ត្រព្រះចៅរាជាធិរាជ ហើយទ្រង់បានស្គាល់ជាក់ជាមនុស្សមានរស្មីប្លែកយ៉ាងអស្ចារ្យ ដូចដែលទ្រង់បានទតឃើញក្នុងព្រះសុបិននោះឯង ៗ ព្រះចៅរាជាធិរាជ មានព្រះរាជហឫទ័យត្រេកអរ

ទាំងពារាណសី ទើបទ្រង់ចាត់ឲ្យគេសាងវត្តមួយនៅជិតទ្វារក្រុងរបស់ទ្រង់ លុះដល់ទ្រង់សោយព្រះទិវង្គតទៅ គេបានដំកល់ព្រះពុទ្ធរូប ១ ព្រះអង្គ នៅក្បែរផ្នូររបស់ទ្រង់ ។

តាមដោយពិតនោះ មានរឿងកើតជំណាលថា ក្នុងកំឡុងសត-វត្សរ៍ទី ២ នៃគ្រិស្តសករាជនោះ នៅប្រទេសចិនមានគណសង្ឃពុទ្ធ-សាសនាកើតប្រាកដឡើងហើយជាដំបូង ។ កាលពីក្នុងរជ្ជព្រះចៅកជាមិកដហ្វេន-ទី នៅក្នុងឆ្នាំ ១៦០ នៃគ្រិស្តសករាជនោះ មានភិក្ខុបណ្ឌិតពីររូបដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ បានចាត់កសាងអាគមពុទ្ធសាសនា ១ ឡើង នៅជិតស្រុកឡោ-យ៉ាំងជាទីក្រុងរបស់ហានក្នុងជាន់ក្រោយ ។ គឺរូបរបស់ភិក្ខុទាំងពីររូបនោះ នាំឲ្យលោកសង្ឃពុទ្ធ-សាសនារូបឯទៀតៗ ដែលមានកំណើតនៅប្រទេសឥណ្ឌា ឬនៅដែនអាស៊ីកណ្ដាលយកគម្រាប់តាមរឿងៗមក ។ ដល់មកខាងចុងសតវត្សរ៍ទី ៣ គួរកត់ថា មានគណសង្ឃកុះករចំរើនឡើងហើយនៅប្រទេសចិន ។ ក្នុងសតវត្សរ៍តៗមក ព្រះពុទ្ធសាសនាជាសាសនាចំរើនឡើងតាមសម័យនិយម តែលទ្ធិតៅអ៊ិស្ទ និងសីលធម៌របស់ខុងជឺបែរជាវៀរពោយទៅវិញ ។ នៅប្រទេសចិនខាងត្បូង នៅក្នុងអំណាចគ្រប់គ្រងរបស់ព្រះរាជាធិរាជពួកលាង ដែលតាំងទីក្រុងនៅណាន់គាំងចំណែកភាគខាងជើង ព្រះពុទ្ធសាសនាក៏ចំរើនឡើងនោះ

មកពីការជួយឧបត្ថម្ភដោយសទ្ធាជ្រះថ្លារបស់ពួក "ស្តេចកឝវង្សវ៉ី" (ROI DE WEI) ជាកឝវង្សរបស់ជាតិមញ្ជូ ដែលបានគាំទ្រក្រុងយ៉ាងខ្ជាប់ខ្ជួននៅស្រុកតាន់-ស៊ី និងហ៊ូ-ណាំន ។ សេចក្តីចំរើនដែលសាសនាថ្មីនាំចូលទៅក្នុងស្រុកចិន ចាប់តាំងពីសតវត្សរ៍ទី ៣ មកនោះមិនជាយឺតយូរទេ ដោយការផ្សាភ្ជាប់ខាងលទ្ធិសាសនាជាមួយនឹងប្រទេសឥណ្ឌា ជាដែនស័ក្តិសិទ្ធិរបស់ព្រះពុទ្ធសាសនា ។ គឺថាប្រទេសឥណ្ឌាដែនពុទ្ធសាសនាហ្នឹងឯង បានផ្ញើបញ្ជូលវិញ្ញាណក្ខន្ធរបស់ខ្លួនទៅក្នុងប្រទេសចិន ។ ហេតុនេះរវាងប្រទេសទាំងពីរកើតចំរើនឡើងក្នុងដែនទ្វីបអាស៊ីដ៏មានទំហំបណ្តោយទទឹងយ៉ាងធំសំបើម, ក្នុងការយើតយោងគ្នាទៅវិញទៅមក ឲ្យបានចំរើនខាងផ្លូវចិត្តគំនិតនោះ មិនមានវៀរពេយសោះឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ ថែមទាំងសម្ព័ន្ធភាពរវាងប្រទេសឥណ្ឌានិងប្រទេសក្នុងទ្វីបអាស៊ី ខាងរបៀបចិត្តវិជ្ជាក៏កាន់តែដុះដាលចំរើនឡើងទៀតនិងខ្ជាប់ខ្ជួនឡើងទៀតជាប្រចាំ ។

— ២ —

នៅខាងចុងឆ្នាំសតវត្សរ៍ទី ៤ នោះ មានពួកលោកសង្ឃចិន ១ ក្រុម នាំគ្នាចេញដើរទៅប្រទេសឥណ្ឌា ដើម្បីស្វែងរកចម្លងគម្ពីរដីកានិងសិក្សាសិក្ខាវិន័យ ក្រោមការត្រួតត្រាពួកគ្រូដែលមានឈ្មោះល្បី

ល្បាញ ៗ ក្នុងចំណោមលោកទាំងនោះ មានលោកសង្ឃ ១ អង្គ ឈ្មោះហ្វា-ហៀន ដែលមានបញ្ញាដ៏មុតមាំ ព្រមទាំងមានចំណេះចេះដឹងអក្សរសាស្ត្រយ៉ាងចំណាប់ ហើយជាអ្នកមានសន្តានចិត្តចេះពិនិត្យការយ៉ាងហ្មត់ចត់ផង ។ ការធ្វើដំណើររបស់លោកហ្វា-ហៀន អស់វេលាជាង ១៥ ឆ្នាំ ទើបត្រឡប់មកស្រុកចិនវិញតាមផ្លូវទឹក ហើយបានចូលសំចតនៅកោះស៊ីឡង់និងកោះជ្វា ដល់ចេញដំណើរតមកដល់ស្រុកចិនទៀត ទើបលិចនាវនៅជិតឈូងសមុទ្រតាន់-ទុង ។ លោកបានរៀបរៀងជាសេចក្តីរាយការ ១ អំពីពុទ្ធសាសនាដែលលោកបានឃើញទាំងប៉ុន្មាននោះ ។ លោកនេះហើយដែលបើកផ្លូវឲ្យពួកក្រុមអ្នកដំណើរទៅកាន់បូជនីយដ្ឋានដែលជាជាតិចិន ១ ក្រុមធំ (នាំគ្នាធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌាក្នុងកាលតមក) នៅក្នុងចំណោមលោកទាំងនោះ មានលោក ១ រូបឈ្មោះហួន-ឆាង ជាធម្មសាមី ជាអ្នកមានកេរ្តិ៍ឈ្មោះល្បីបំផុត ៗ

លោកហួន-ឆាង កើតនៅក្នុងសតវត្សរ៍ទី ៦ ប្រហែលជាពេង ឆ្នាំ ៥៩៦ ជាប្រាកដ ។ ក្នុងត្រកូលអ្នកប្រាជ្ញហើយជាពួកមន្ត្រីជាន់ខ្ពស់ ហើយមានចំនួនមន្ត្រីជាច្រើនបានទទួលដំណែងខ្ពស់ ៗ ក្នុងរជ្ជកាលព្រះរាជាធិរាជហានទីង្វី ៗ ឪពុករបស់ហួន-ឆាង ជាមនុស្សស្លូតបូតទៀងត្រង់ណាស់ហើយជាអ្នកប្រាជ្ញផង ។ លោកហួន-ឆាងលះបង់ផ្លូវលោក ហើយចេះដឹងស្ទាត់ជំនាញក្នុងការមើលគម្ពីរ និងបកប្រែសេចក្តី

ជាទីពាស់ៗផង ។ ហេតុនេះបានជាហួន-ឆាង មាននិស្ស័យសន្តានចិត្តលំអៀងទៅខាងសាសនា តាំងពីក្មេងមក (ដូចសន្តានចិត្តរបស់មាតុក) ។ លោកមានអាយុមិនទាន់គ្រប់ ១៣ ឆ្នាំផង ក៏បានសុំចូលទៅស្នាក់នៅវត្តយាយដំពូខសាសនា នៅស្រុកលោយ៉ាង ។ លោកនៅទីនោះបានសិក្សាធម៌ដែលត្រូវនឹងសន្តានចិត្តរបស់ខ្លួន គឺលទ្ធិនាម-ធម៌ក្នុងមហាយាន ហើយបិតនៅស្មោះត្រង់ក្នុងលទ្ធិនេះរហូតអស់ ១ ជីវិត ។ ដល់អាយុ ២០ ឆ្នាំ គេទទួលឲ្យទៅនៅក្នុងស្រុកចេង-ទូ ទីក្រុងរបស់ខេត្តសេ-ឈួន ដើម្បី "បំពេញសិក្ខាវិន័យ" ។ តាំងពីនោះមក ក៏មានកេរ្តិ៍ឈ្មោះល្បីល្បាញធំឡើង ។ ការល្បីឈ្មោះនោះនាំឲ្យជឿថា ក្នុងប៉ុន្មានឆ្នាំដែលលោកហួន-ឆាងបានបួសហើយនោះ គេមិនដែលហៅលោកដទៃក្រៅពីពាក្យថា "ធម្មសាមី" ឡើយ ។ លោកហួន-ឆាងជាអ្នកចេះពិនិត្យពិចារណាយ៉ាងហ្មត់ចត់ ហើយជាអ្នកស្ទាត់ជំនាញក្នុងភាសាអ្នកស្រុកយ៉ាងពូកែផង លោកមានសិស្សគណនិងសាវកជាចំនួនច្រើន ។ លោកមានចំណេះចេះដឹងមុតមាំខាងវិន័យ, សាស្ត្រា និងព្រះសូត្រទាំងឡាយហើយ ក៏នៅតែមិនទាន់ពេញចិត្តលោកនៅឡើយ ។ សេចក្តីសង្ស័យផ្សេងៗ នោះនាំឲ្យលោកដឹងខ្លួនជានិច្ច ។ លោកចេះដឹងនានាទិដ្ឋិតៗ ក្នុងលទ្ធិសាសនាទាំងឡាយ ដែល

លោកបានសិក្សាយ៉ាងជ្រៅជ្រះហើយយល់ថា ដើម្បីនឹងបញ្ចប់បំផុតត្រង់ការយល់ប្លែកៗ គ្នានោះ ត្រូវតែលោកសិក្សាដល់ដើមកំណើតនៃលទ្ធិទាំងនោះ ទឹងរបៀបការរៀនសូត្រនៅក្នុងប្រទេសដែលជាដើមកំណើតនៃលទ្ធិទាំងនោះផង ។ លោកសម្រេចដាច់ចិត្តថា ត្រូវតែចូលទៅក្នុងប្រទេសឥណ្ឌា ដូចជាលោកពុទ្ធឈ្មោះហ្វា-ហៀនធ្លាប់ធ្វើមកហើយកាលពី ២ សតវត្សរ៍មុនលោក ។

កាលពីក្នុងឆ្នាំ ៦២៩ នោះ លោកហ្វូន-ឆាំងសម្រេចដាច់ស្រេចថានឹងចូលទៅគាល់ (ព្រះរាជាធិរាជចិន) ដើម្បីសុំព្រះរាជានុញ្ញាតធ្វើដំណើរចេញទៅ ។ គ្រានោះ ព្រះរាជាធិរាជដែលគ្រងរាជសម្បត្តិប្រទេសចិន មិនតែអ្នកដទៃក្រៅអំពីព្រះមហាតៃ-ធុង ដែលទ្រង់មានជ័យជំនះឈ្នះពួកតួរក៍ ហើយទ្រង់ជាអ្នកតាំងរាជវង្សថ្មីរុងរឿងឡើងហៅថា ពួកវង្សតាំង ។ ការទូលសុំអនុញ្ញាតរបស់ភិក្ខុពុទ្ធសាសនាបែរជានាំឲ្យមានការទោធដល់ទ្រង់ទៅវិញ ទើបទ្រង់ធ្វើយតបដោយចេញជាព្រះរាជបញ្ញត្តិ១ ហាមប្រាមយ៉ាងដាច់ខាត ។ ឯលោក ហ្វូន-ឆាំង គឺមិនមានរញ្ញកទេ តែលោកដកខ្លួនចេញទៅនៅក្នុងប្រាសាទមួយតែឯកឯង ហើយចំរើនមេត្តាភាវនាជារហៅយូរនៅទីនោះ មានពពួកសត្វដែលគេមើលមិនឃើញចោមរោមជុំវិញទាំងយប់ទាំងថ្ងៃ (មានត)

# ច្បាប់ព្រះឥន្ទ្រលវែង

## បទកាកគតិ

នេះហែងជាច្បាប់ ខ្ញុំនាំមហាគាថ តែងជានិទាន តាមដោយគន្លង ព្រេងព្រឹទ្ធបុរាណ ប្រាជ្ញលោកនិពាន ប្រដៅបុត្រា ៗ ហៃកូនពន្លក ស្ងួនអើយបាយក បណ្ដាំបិតា ដីពុកនេះចាស់ ឥតអ្វីឲ្យបា ស្ងួនាអើយរក្សា ពាក្យដីពុកនៅ ៗ ឲកូនកុំសត់ រៀនខុនរៀនអត់ រៀនគិតគិតក្រៅ រៀនខុនលំពោន កុំឲ្យកាសោ-ហ្មងដល់ខ្លួនចៅ កើតដល់ជនក ៗ ដីងក្ដើយផ្សិតផង កូនសោតវែងគ្គង-ផ្សិតតែអាពុក ទ្រព្យនងផ្សិតស្រី បេះរៀបដាក់ទុក ប្រះដេកធាប់លក់ ផ្សិតផកបើគិត ៗ ចំណេះទាំងឡាយ[1] កិច្ចកល់ដោះស្រាយ ផ្សិតតែគំនិត ដឹងកិច្ចដឹងកល់ ដឹងឆ្ងាយដឹងជិត ដូចកល់តាំបិត កាប់ភ្លាំចំណាយ ៗ ល្មមតៅល្មមខាន ល្មមដើរបំពាន កុំគិតត្រង់ឆ្ងាយ ល្មមឈប់បង្អង់ ល្មមខាននៅកាយ ក្ដីក្រកុំស្រាយ ក្ដីឆាយកុំច្រួស ៗ ស្លូវដើរកុំដេក ស្លូវឈប់កុំតេក សេចក្ដីប្រហែស ស្លូវខានកុំកាវ បរើងបរេស ស្លូវចូលកុំបៀស កសរួចសិមគួរ ៗ លឿនកុំបំពោល ពាក្យព្រេងកុំពោល ខឹងកុំទ្រូ ស្រាយបញ្ចៀទ្រពាប់ កុំឲ្យទុកយូរ សេចក្ដីនោះធូរ ខឹងដឹងខុសត្រូវ ៗ ដេកកុំដំណើច តេក្រកុំសើច តេភ័យកុំព្យាហ៍ ពោះទីង

---

១. ច្បាប់ខ្លះថា ចំណេះទាំងឡាយ ។

ប៉ុន្មាន ធ្វើបានឲ្យគួរ គិតគិតឲ្យល្អ យូរពេកឲ្យឆាប់ ។ សេចក្ដីសំរុង ពាក្យដើមពាក្យចុង ប្រកាន់ឲ្យខ្ជាប់ សូវទៀមឯខ្លួន កុំឲ្យបង់ទ្រព្យ សូវបង់ក្ដីអាប់ កុំឲ្យខ្លួនស្លាប់ ។ សូវស្លាប់ទៅជា កុំបង់ធម្មា ឥរិយា ស័លអាប់ ឲ្យគិតជញ្ជីង រំពឹងឲ្យសព្វ ពាក្យស្មើកុំស្មប់ ពាក្យគាប់ឲ្យ យក ។ ពង់ជូនឲ្យទុក[1] បង់បានក្ដីសុខ ឲ្យស្មើដើរក ឃើញច្បាប់ ផមិផង ឲ្យយកខ្លួនជក ក្ដីសោកមះម៉ាក ឲ្យបៀសបេញឆ្ងាយ ។ កូន អើយលោកិយ នេះឲ្យរៀនក្ដី រៀនច្បាប់ទាំងឡាយ រៀនទាំងសំដី កុំប៊ិកយមាយ ក្ដីក្រក្ដីងាយ ក្ដីភ្លេក្ដីសម ។ ទុកូនពុំង៉ា ធម្មតាអ្នកជា រៀនថៃរៀនទាំ រៀនដាក់រៀនទុក រៀនរៀបរៀនចំ រៀនកេសន្សំ លក់បេញទិញចូល ។ មួយអោតឯច្បាប់ បើបានមានទ្រព្យ មនុស្ស ផងមូតមូល ពឹងពាក់បានណា បានយកប្រមូល សន្សំផ្សំប្រូល យក មកជាគ្នា ។

កូនអើយឯម្ដប់ មនុស្សផងចូលលាប សម្រាន្តអាត្មា ព្រោះឈើ កានម្ប់ គ្រាំសាខា ម្ដេចឡើយប្រែជា ក្ដៅជ្រកពុំបាន ។ មនុស្ស ផងម្ដង់ គេម្ដប់ទៀតបោង ចូលចតសម្រាន្ត ម្ដប់នេះត្រជាក់ ត្រសាក់ក្សេមក្សាន្ត មនុស្សផងចូលបាន មិនមានហៅអាក ។ ឲបមាដូចទឹក ជ្រាលជ្រៅពន្លឹក ជាទីសំណាក់ មច្ឆាទាំងឡាយ បេញ

១ ច្បាប់ខ្លះថា បង់មានឲ្យទុក ។

ចូលពីងពាក់ ព្រោះទឹកត្រជាក់ មិនមានហ៊ានសៅ ។ ពុំដឹងឡើយឯ
ទឹកម្ដេចមកថែរ ប្រែទៅជាក្ដៅ មច្ឆាទាំងឡាយ ព្រាត់ព្រាយរត់ទៅ
រកទឹកទៀតនៅ សំណាក់គាត្នា ។ កូនអើយបើបោះ អសារគ្រៃឈ្មោះ
ត្រូវត្រង់ខ្លួនបា ព្រៀងលានទាំងឡាយ គេនឹងនិន្ទា ជំងៀលដៀលថា
បាឯងពុំបេះ ។ ស័ប្បុរសគប្រាជ្ញា ស័ប្បុរទាំងឥរិយា ពោលចំពោះ
ស័ប្បុរទាំងមារយាទ ស័ប្បុរទាំងជម្រះ ដ្បិតបាឯងនេះ ពុំបេះរក្សា ។
គួរនាដូចទឹក កូនអើយបើល្អក ពុំមានមច្ឆា គួបមួយឈប់ជ្រក នៅ
កង់គង្គា ពុំកប់ហៅថា ប្រែសើរឡើយហោង ។ មួយសោតអ្នកណា
គេមកប្រាប់ថា ដ្បិតបាធ្វើផ្គង់ បាគិតជញ្ជឹង រំពឹងដើមទង កុំបាផ្ដោះ
ផ្ដង ផ្ដៀងផ្ដងពុំស្ដាប់ ។ ទូកហូសកំពង់ កាថែរបង្អង់ ថយមកចូល
តាប់ ពាក្យលឿនហួសខ្នាត ហៅឥតគំនាប់ ថយមករកគាប់ ពុំបាន
ឡើយណា ។ អន្ទុយហួសស័ក្តិ ស្រដីហួសថ្នាក់ ចង់បោយហួសស្នា
ពុំមើលប្រមាណ ឧង្ប្រាណកាត្នា បាហួសបង្ក្រា ថាហួសសេចក្ដី ។
រំងុកផ្ដើម មុខដូចគេពេច បារឡើងស្រដី អួតឯងកំឡាំង ដល់
ឧស្ដង់រ៍ ពោះទាំងពងសិហ៍ កឹអញមិនខ្លាច ។ មួយសោតបបក ដក
ក្របកអក[១] អួតឯងអំណាច ឧស្ស័ដកប្រើបរី ទៅខាំទាគពជ ជរណ្ដម

---

១ ច្បាប់ខ្លះថា ក្អុកក្រអក ។

យកពាក្យ កុម្មុកតនាគា ។ វិសេតុអណ្ដើក ការឡើងលើកៗ មកអួត គាថា ជាអញ្ចឹងលោក រំលងបព្វតា ហេតុក្ដីមោហា ពុំដឹងខុស នាប់ ។ វង្វេងគិតក់ លោកឡើងពីកត់ មើលទៅគួរស្អប់ អួតខ្លួនជាល្អ ដូចមាសទឹកដប់ ពង្រអាញចំប្រែប់(១) ដូចកជសីហា ។ ហាឡើង មិនបាន ស្ដីមិនប្រមាណ ទំងអង្គគាថា សូវទេកុំដើប សូវស្ងៀម កុំថា សូវគេចកុំការ សូវគាប់កុំខ្វេស ។

ឱកូនពន្ធ ច្បាប់នេះថាយក ស្គន់កុំប្រហែស ច្បាប់នេះប្រសើរ ហៅមហាពិសេស កូនអើយកុំធ្វេស ទំងច្បាប់នេះណា ។ មួយសោត ឯល្បែង សប្បាយចង់លេង ទំងមានកយា ទំងកើតទុក្ខក្រោយ ទំង បង់ទ្រព្យា ទំងកើតគន្ធា ៗ បង់ការយាទគាប់ ។ សប្បាយធ្វើស្រែ ចម្ការជួញប្រែ នោះមានគេរាប់ សប្បាយមានធ៌ សប្បាយមានទ្រព្យ សប្បាយនោះគាប់ សប្បាយយឺនយូរ ។ មួយសោតឯស្រី បេះលើក ចេសប្ដី បេះគិតបេះគួរ បេះរៀបបេះចំ ឲ្យសមទំងគួរ អ្នកផងទំង សួរ រកឈ្មោះពុំមាន ។ នាងនោះឈ្មោះអ៊ី មុខមាត់ប្រិមប្រិយ៍ សមជាអ្នកមាន ម្ល៉ោះហើយទំងកើត ទ្រព្យធនមិនមាន ព្រោះពាក្យ សន្ដាន ព្រៀងលានគេតាយ ។

១ ច្បាប់ខ្លះថា កាអញចំប្រប់ ។

៚ រីឯពាក្យមនុស្ស កុំជេលទឹងខុស ហួសពីទំនាយ កុំជេលខឹង ល្អៀង មិនជិតមិនឆ្ងាយ អ្នកផងទាំងឡាយ គួរគិតកុំច្រល់ ។ ពាក្យព្រេងលោកថា លោកមានឧបមា ឲ្យគិតឲ្យយល់ ពាក្យលោកទំនឹម មិនមានឲ្យសល់ កូនអើយកុំច្រល់ ទឹងពាក្យនេះណា ។ កុំអួតកុំអាង ដើរកុំមើលកង មើលអគ្គគាគ្នា កុំដើរផ្ទះគេ ហួសពេលវេលា កុំទៅជានា ទ្រព្យគេទាំងឡាយ ។ កុំដេកផ្កាប់មុខ កុំដើរពានថ្នក ថាឯងសប្បាយ មានទោសទឹងគេ កុំឲ្យនិយាយ ដើមគេទាំងឡាយ ទឹងកើតទោសធំ ។ ខ្លួនទាបកុំគោង ដៃខ្លីកុំឈោង ប្រាថ្នាបក្ខំ ចាស់គោងកាន់ប្រាក់ អួតអាងប្រាក់ ក្រអួតផ្ទុំ ប៉ុពកយកខ្យល់ ។ ខ្វាក់ធ្មុះកញ្ចក់ ជកកក្រង់ក់ ហាក់ឯងមើលយល់ ខ្វិនអួតទឹងផ្ទោះ រំលងលើគល់ ទំពែករកគល់ ចង់បានប្រេងលាប ។ ក្រវែនចង់កំ ក្រោកឡើងទន្ទ្រាំ ចង់គោងអាចឡាប ថ្លង់ចង់ស្តាប់ប្រៀន ផ្អូងផ្អៀងទន្ទាប ថែកួបខ្លួនទាប ចង់ឈោងចាប់ផ្កាយ ។ កូនអើយចូរស្តាប់ ពាក្យនេះមហាគាប់ គ្រប់ត្វាទាំងឡាយ បាគិតជញ្ជីង រំពឹងឲ្យឆ្ងាយ កុំធ្ងើកយមាយ ទឹងច្បាប់នេះណា ។ មួយសោតគេប្រាប់ ថាបាពុំគាប់ ទោសផលគាគ្នា កុំបាក្លឹកក្លាំង ស្វន់ស្វាំងកាយា ប្រុងប្រាណករិយា ស្មារតីឲ្យនឹង ។ រះរកគំនិត ផ្ចុំឃោបល់គិត ទង់ទាញសន្ទឹង ប្រាជ្ញាមួយគិត ថាខ្សៀនឲ្យដឹង ដម្រិះមួយរំង ធ្វើហាក់មិនក្លឹក ។

កូនអើយលោកថា ពាក្យលោកឧបមា ដូចគជសីហ៍សឹក កាំភ្លើង ជ័យជំ កុំដែលទឹងកឹក ចំញួបគតិក គគុកបោលចូល ។ ធម្មតាអ្នកជា អ្នកមានប្រាជ្ញា សន្តានត្រកូល ឲ្យគិតឲ្យដឹង រំពឹងឲ្យមូល ប្រាជ្ញាមួយចូល បង់ចាំទុកទៅ ។ កុំអួតកុំអាង កុំភូតបំព្រាន កុំឲ្យវែបចូវ កុំកាចកុំកិន រអើរអួរ កុំនាំពាក្យទៅ ប្រាប់ឲ្យកើតទោស ។ កុំវេះកុំវៀន កុំបៀតកុំបៀន កុំស្ដីគោសម៉ោស គ្នាបានជាខុស ឲ្យមានសន្ដោស កុំហាឲ្យហួស ផ្ដួសពាក្យទៅមុខ ។ ចូលសឹតកុំញោប ជំពាក់កុំបោប វិលកុំបង់ពន្ធ ទឹងគ្រាគ្នា កុំឲ្យលោកអន់ សេចក្ដីចម្ងន់ សន្សំកុំបោល ។ កុំអួតកំឡាំង កុំអាងខ្លួនខ្លាំង រកនឹងស្រមោល កុំអាងខ្លួនធំ កុំវាយពាក្យពោល ពាក្យព្រែនកុំពោល កុំពោលទោសសង្ស័យ ។ កុំពោលផ្លូវវៀច កុំអាងអំណាច ដើរគាត់ផ្ទែង វែកងបង់ភរិយា សក្ដាពុំគង់ លោកហៅថាល្ងង់ អប្បឥតប្រាជ្ញា ។

កូនអើយចូរស្ដាប់ ពាក្យនេះចាំគាប់ មានមិត្រស្នេហា ឲ្យមើលអាយោច មើលសព្វកិរិយា ឲ្យដឹងជាក់ជា ការប្ដូរវៀចត្រង់ ។ ឲ្យសមឲ្យស្រួល ឲ្យល្មមនឹងខ្លួន ឲ្យដូននឹងគន្ធ សមយកជាមិត្រ ស្និទ្ធស្នេហ៍ដ៏ល្វង់ ទៅមកដម្រង់ ចេញចូលធំចុក ។ មិត្រមួយសោកណា ទៅមកការគ្នា បង់ឲ្យកើតសុខ មិត្រមួយឲ្យទោស បង់ឲ្យកើតទុក្ខ

មិត្រមួយឲ្យទុក ឲ្យបាត់បង់ទ្រព្យ ។ ទុកកូនពីរ កូនប្រុសកូនស្រី
កូនហើយបាស្លាប់ ទំនៀមទំនង គន្លងផ្លូវច្បាប់ ទុកជាសណ្ដាប់ នៃ
នរជនជាតិ ។ មួយៈសោតលោកថា បុគ្គលអាត្មា មាន ៣ ពុំឃ្លាត
មួយចិត្តមួយៈដេក មួយដើរជាខ្នាត ចិត្តកេរយាទ ពុំត្រូវសណ្ដាប់ ។
ដើរតែតបើគិត ដើរតែតក់ទិត ហៅខុសនឹងច្បាប់ ដេកដល់ថ្ងៃរះ
ហៅឥតគំនាប់ ចង្រៃអភ័ព្វ នឹងជាប់អាត្មា ។ នឹងស្មុគរកទ្រព្យ
ចង្រៃអភ័ព្វ មិនឲ្យជំនា ឲ្យកើតតែទោស នឹងបង់ទ្រព្យា នឹងរក
ក៏រំហោ ហាក់ដូចគេណាយ ។ ព្រោះក្ដីអភ័ព្វ ចង្រៃនូវអត-
មង្គលទាំងឡាយ ចូលគង់អាត្មា មិនមានទៅឆ្ងាយ ជ្រួតជ្រាបក្នុង
កាយ គង់អង្គអាត្មា ។ ទោះប្រុសទោះស្រី បើមានបុក ៣ ដូច
ច្បាប់លោកថា បុកដើរបុកដេក បុកឆីអាហារ ជាអ្នករក្សា ភរិយា
មារយាទ ។ ខ្លាចមេខ្លាចបា ទោះបំរើការ មិនមានឲ្យឃ្លាត
ទោះបីនឹងលើក ទ័ពលើងមានខ្នាត ជាអ្នកសង្ក្រាត ទំឃ្លាតធ្វើការ ។
អ្នកផងទាំងឡាយ ទោះជិតទោះឆ្ងាយ គេយកភរិយា គេយកបំណោះ
ជាអ្នកសៀមសា គេចង់បានបា បងពន្ធជាញាតិ ។ មានខ្លះត្រ
ពុំគិត យកតែគំនិត ភរិយា មារយាទ. យកតែរបៀប រៀបចំ
ជាខ្នាត សព្វាហ៍សង្ក្រាត រក្សាទ្រព្យា ។ រង្គាយអាពុក នឹង

បានលើកមុខ ឲ្យកូនពុំឆ្ងា ទាំងអស់បងប្អូន ជីដូនជីតា ម្តាយ
មីងនូវឪ សឹងស្រលេបូលចិត្ត ៗ ដ្បិតកូនសុភាព ជាអ្នកឥតបាប
ត្រូវទីងគំនិត គ្រប់អស់បងប្អូន ទោះឆ្ងាយទោះជិត សរសើរគំនិត
បានេះឯងណា ៗ

កូនអើយចូរស្តាប់ ចូរចាំឲ្យខ្ជាប់ ទុកនៅអាត្មា ទំនឹមទំនង
តទង់ឧបមា ព្រះពុទ្ធទេសនា ទូន្មានសត្វហោង ៗ

ចប់ច្បាប់ព្រះបន្ទូលចែងតែប៉ុណ្ណោះ

ព្រះគ្រូមុនីសោភ័ន សោម-ឡុច ក្រុមជំនុំព្រះត្រៃបិដក

ទៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

# អំពីរបស់ពីរនាំបំផ្លាញរបស់ច្រើន

ក្នុងលោកនេះ មានជនបំពួកខ្លះ ច្រើនប្រកបដោយសេចក្ដីលោភ ដែលជ្រុលហួសប្រមាណ ចង់មាន ចង់បានខ្លាំងពេក ឥតគិតមុខគិតក្រោយ ឥតយល់មុខនរណាជានរណា ឲ្យតែប្រទះដៃត្រង់ណាយកត្រង់ណឹង គិតខាងឲ្យបានតែចំណូលនឹងចំណេញ ត្រង់ចំណាយ ឬក៏វិនាសអន្តរាយចង់ខាតទៅវិញ មិនគិតផងសោះ ជនបែបនេះលោកហៅថា ឆ្អិនក្បាល ស៊ីក្បាល ឆ្អិនកន្ទុយ ស៊ីកន្ទុយ ទីងយកជាការប្រមាណមិនបាន ។

មួយទៀត ក្នុងត្រៃភព ទោះវត្ថុមានវិញ្ញាណក្ដី ឥតវិញ្ញាណក្ដី មានរូបក្ដី ឥតរូបក្ដី សុទ្ធតែមានហេតុមានទំនង ល្មមឲ្យគិតឃើញបានទាំងអស់ ព្រោះរបស់ទាំងនោះសុទ្ធមានជាគូៗ ទីងគ្នាហូរហែមកជាធម្មតា ដូចពាក្យថា "បុណ្យគូនឹងបាប គុណគូនឹងទោស សុខគូនឹងទុក្ខ ល្អគូនឹងអាក្រក់ បានគូនឹងបង់ឬបាត់ទៅវិញ" រួមខ្លីថា បុណ្យបាប គុណទោស សុខទុក្ខ ល្អអាក្រក់ បានបង់ ឬបាត់ទៅវិញ ប៉ុណ្ណោះជាដើម ។

ជនអ្នកមានបញ្ញា ស្ងួតត្រិះរិះគិតរបស់ទាំងនោះ កុំឲ្យជាប់ចំពាក់ ដើម្បីការពារកុំឲ្យទុក្ខគ្របសង្កត់ខ្លាំងពេក បើមិនបានគិតទុកជាមុនទេ ដល់ពេលមានគ្រោះថ្នាក់ធ្លាក់មកដល់ខ្លួនម្ដងៗ ចិត្តរំញាប់ញ័ររន្ធត់តក់ស្លុតស្លន់ស្លោសន្ធែងសន្ធៃ គាំងឡោះអាល័យសោកស្ដាយពេកណាស់ បើបានបុណ្យយសស័ក្តិជាធំហើយ កុំស្រវឹងស្រវើងភ្លេចខ្លួនពេក ត្រូវគិតដល់បាបគឺអំពើលាមកណាមួយដែលជាហេតុនាំខ្លួនឲ្យសាបសូន្យទៅវិញផង មានគុណធម៌ល្អក្នុងខ្លួនហើយ ត្រូវគិតដល់ទោសផង បានសុខស្រួលហើយ ត្រូវគិតដល់ទុក្ខផង បានល្អហើយ ត្រូវគិតដល់អាក្រក់ផង កេរ្តិ៍ទ្រព្យសម្បត្តិបានហើយ ត្រូវគិតដល់ការណ៍វិនាសបង់ខាតទៅវិញផង ហេតុបានជាឲ្យគិតដូច្នោះនោះ ព្រោះវត្ថុទាំងមានវិញ្ញាណ ឥតវិញ្ញាណដែលកើតមានក្នុងត្រៃភព សុទ្ធតែជារបស់មិនទៀង រមែងផ្លៀងត្រឡប់ផ្កាប់ចុះចូលមកនៅក្នុងផ្លូវព្រះត្រៃលក្ខណ៍ទាំង ៣ គឺអនិច្ចំ ទុក្ខំ អនត្តា ទាំងអស់ គ្មានសល់ ១ ឡើយ លើកតែឋានព្រះនិព្វានចេញ ក្រៅពីឋានព្រះនិព្វានហើយ កុំសង្ឃឹមថាបានសុខស្រួលល្អនោះ គ្មានទេ តែងតែប្រែប្រួលវិនាសសាបសូន្យទៅវិញជាធម្មតា បើជនណាមិនបានគិតគូររបស់ទាំងនោះទេ ត្រូវឡប់ទៅជាបណ្ដែតបណ្ដោយឲ្យចិត្តជ្រុលលង់ជាប់ក្នុងអារម្មណ៍ណាមួយហើយ ជននោះឯងមិនងាយនឹងទាញចិត្តឲ្យបានដូចស្រឡះមកវិញឡើយ ត្រូវតាំងចិត្ត

ជាកណ្ដាលៈទើបបានល្អ គឺថាកុំស្រឡាញ់ពេក កុំមិនស្រឡាញ់ពេក កុំអរពេក កុំមិនអរពេក កុំសប្បាយពេក កុំមិនសប្បាយពេក ការបើស្រឡាញ់របស់ណាខ្លាំង ទុក្ខក៏ខ្លាំង ស្រឡាញ់យ៉ាងល្មម ទុក្ខក៏ល្មម ស្រឡាញ់បន្តិចបន្តួច ទុក្ខក៏បន្តិចបន្តួច បើមិនស្រឡាញ់សោះ ទុក្ខក៏គ្មានដែរ ។

អធិប្បាយថា: ដូចជាមាតាបិតាស្រឡាញ់បុគ្គលណាមួយដែលជាទីពេញចិត្ត ស្មើនឹងបាត់ពីមុខមិនបាន វេលាណា បុគ្គលនោះមានជម្ងឺឈឺចាប់ ស្លាប់បាត់បង់ទៅ ឬមួយក៏ព្រាត់ប្រាសទៅនៅទីណា ៗ បាត់ទៅ ក៏កើតទុក្ខទួញយំសោកស្ដាយខ្លាំងពេកណាស់ ១០ ឆ្នាំ ២០ ឆ្នាំទៀតទៅ ក៏មិនងាយនឹងបាត់ទុក្ខនោះឡើយ នេះហៅថាស្រឡាញ់ខ្លាំង ទុក្ខក៏ខ្លាំង ព្រោះហេតុនោះ បានជាពន្យល់ថា ត្រូវធ្វើដំកល់ចិត្តជាកណ្ដាល បើមិនដំកល់ចិត្តជាកណ្ដាលទេ ពេលណាកែមានគ្រោះថ្នាក់ប៉ះមកដល់ម្ដង ៗ ក៏កើតទុក្ខយ៉ាងខ្លាំង ដូចគេផ្ទឹមយកប្រៀបផ្ទឹមពុំបានដូចស្វានឹងត្រាប់ពោត ។

## អំពីរឿងស្វានិងត្រាប់ពោត

សូមដំណាលរឿងនោះ ដោយសង្ខេប តាមសេចក្ដីក្នុងគាថាយមុដ្ឋជាតក ទុកខបាតថា "ក្នុងអតីតកាល កាលកន្លងទៅហើយ

គ្រានោះមានស្តេចមួយព្រះអង្គ ទ្រង់ព្រះនាមព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី ។

វេលានោះ ព្រះពោធិសត្វទៅជាអាមាត្យគាល់បំរើទ្រង់ប្រឹក្សាធម៌ថ្វាយស្តេចនោះ ។ មានកាលសម័យថ្ងៃមួយ ព្រះបាទព្រហ្មទត្តស្តេចលើកពួកពលសេនាយោធាចេញទៅបង្ក្រាបស្រុកដែលនាំបណ្ដាលហេតុបះបោរធ្វើជាចោរលួចប្លន់កាប់សម្លាប់ពួកអ្នកស្រុកបច្ចន្តគ្រាម ព្រះពោធិសត្វក៏បានជាប់ទៅជាមួយនឹងស្តេចផងដែរ ពេលនោះ ខេមាន ភ្លៀងក៏ធ្លាក់ជោកជាំជោរជន់ ពេញស្ទឹងពេញអូរហៀរហូរសាយលិចទួលតូចធំ ព្រះបាទព្រហ្មទត្តទ្រង់ស្តេចធ្វើព្រះរាជដំណើរទៅ ក៏លំបាកពេកណាស់ ទើបទ្រង់ស្តេចនាំពួកពលនោះទៅឈប់ក្នុងសួនឧទ្យានដើម្បីនឹងប្រជុំពួកពលឲ្យនឹងចំនួនតិចច្រើន ។

ចំណែកខាងពួកទាហានសេះក៏នាំគ្នាស្រាវគ្រាប់ពោតដ្ឋិនស្រែបជួសស្រង់ទាក់ទៅក្នុងស្បុកដើម្បីឲ្យពួកសេះស៊ី ។ ក្នុងសួនឧទ្យាននោះមានពួកស្វានៅជាច្រើន មានស្វា ១ រំលងខ្លួនជាងគេរះរាមកនឹងចំណី ក្រឡេកមើលទៅឃើញគ្រាប់ពោតស្ងោរថ្មីៗ ក៏មានសេចក្តីចង់ស៊ីខ្លាំងពេកណាស់ អត់ទ្រាំមិនបាន ក៏ស្រមតខ្លួនចុះពីដើមឈើទៅលួចគ្រាប់ពោតនោះពាមពេញក្នុងមាត់ ហើយក្រសាវចាប់ក្ដាប់ពេញ ១ ដៃទាំងពីរថែមទៀត ហើយបោលត្រឡប់ឡើងទៅលើដើមឈើនោះវិញ

ក៏អង្គុយទំពាស៊ីគ្រាប់ពោតនោះ លុះទំពាស៊ីមិនទាន់បានជាប្រើប៉ុន្មាន ក៏ស្រាប់តែគ្រាប់ពោត ១ របូតជ្រុះពីដៃម្ខាង ធ្លាក់របូតដល់ដី ឯស្វាកាឡកណ្ដុំក៏មានសេចក្ដីស្ដាយពេកណាស់ ស្វាខ្ជាក់គ្រាប់ពោតពីមាត់ ទាំងបាចសាចគ្រាប់ពោតពីដៃទាំងពីរចោលចេញអស់ ហើយចុះពីដើមឈើជាប្រញាប់តាមទៅអើតឈ្ងោករកមើលលើផែនដី ក៏រកមិនឃើញ នេះហៅថា សត្វល្ងង់ឥតបញ្ញា សត្វចង្រៃ មិនដែលមាន បានគ្រាប់ពោតពេញមាត់ ពេញដៃ មិនស្ដាយ- ត្រឡប់ទៅស្ដាយពោត ១ គ្រាប់វិញ ត្រូវនឹងពាក្យចាស់លោកថា "ការប៉ុនក្អម មិនគិត ទៅគិតសព្វបើស្ករកំប៉ុកមាត់" យ៉ាងណាមិញ ឯស្វាក៏យ៉ាងនោះដែរ ត្រង់គ្រាប់ពោតច្រើនដែលខ្លួនបាចសាចចោលអស់ មិនគិតស្ដាយ ទៅគិតស្ដាយពោត ១ គ្រាប់ដែលរបូតជ្រុះពីដៃទៅវិញ ក្រុះចំគយគន់រកត្រង់ណោះត្រង់ណោះមិនឃើញ ទើបត្រឡប់ឡើងទៅលើដើមឈើវិញ ក៏អង្គុយសំកុកកើតទុក្ខស្ទើរតែនឹងដាច់ខ្យល់ស្លាប់ ៗ វេលានោះ ព្រះបាទព្រហ្មទត្តស្ដេចទ្រង់ទស្សនាការឃើញកិរិយាស្វាដូច្នោះហើយ ក៏ទ្រង់ត្រាស់សួរពោធិសត្វថា "ហេតុអ្វីបានជាស្វានោះរាអង្គុយសំកុកកើតទុក្ខខ្លាំងម៉្លេះ"? ពោធិសត្វក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ជម្ទាមនុស្សល្ងង់ឥតបញ្ញា ច្រើនបូលចិត្តសំឡឹងមើលរបស់ណាដែលតិចៗ ត្រង់របស់ដែលច្រើនៗ មិនសំឡឹងមើលសោះ ដូចជាស្វានោះឯង

ក៏សុំឡើងមើលតែគ្រាប់ពោត ១ គ្រាប់គ្រង់ពោតច្រើន នៅពេញមាត់ពេញដៃ មិនសុំឡើងមើលទេ ត្រឡប់ជាបាចបោលពេញអស់រលីង ងាកទៅខាងណោះក៏បាត់ ងាកមកខាងណេះក៏បាត់ ព្រោះហេតុនោះ បានជាកើតទុក្ខព្រួយចិត្តខ្លាំងយ៉ាងនេះឯង សូមទ្រង់ព្រះមេត្តាប្រោស ដូចក្នុងពេលនេះ ទឹកនៅក្នុងជោរជន់ខ្លាំងពេកណាស់ មិនឆាយទឹងស្រកទៅវិញទេ ព្រោះភ្លៀងធ្លាក់មករាល់ថ្ងៃៗ, បើព្រះករុណាស្ដេចធ្វើព្រះរាជដំណើរទៅបង្ក្រាបសត្រូវនៅពេលនេះ អស់ពួកពលមុខជានឹងវិនាសដោយទឹកពុំខាន សូមទ្រង់ព្រះមេត្តាប្រោស បុនដំណើងមកជាពួកខ្មាំងសត្រូវនោះគិតដែរទេ ពួកពលឯណោះច្រើនពេកណាស់ សូមព្រះករុណាកុំស្ដេចសុំឡើងមើលទៅរបស់គេ សូមទ្រង់ស្ដេចសុំឡើងមើលមករបស់ច្រើនវិញ ទើបបានសេចក្ដីចំរើនល្អ ។ ស្ដេចបានទ្រង់ព្រះសណ្ដាប់ពាក្យពោធិសត្វនោះហើយ ក៏ស្ដេចទ្រង់អនុវត្តតាម ហើយនាំពួកពលត្រឡប់ចូលមកក្នុងក្រុងវិញ ។ ចំណែកខាងពួកខ្មាំងសត្រូវកាលដែលឮថាស្ដេចលើកពួកពលទៅ ក៏មានសេចក្ដីភ័យគិតខ្លាចអំណាចបារមីនៃស្ដេចនោះពេកណាស់ ទើបនាំគ្នារត់ចូលទៅក្នុងព្រៃបាត់អស់ទៅ " ។

ចប់ កាឡាយមុន្តិជាតក ប៉ុណ្ណោះ ។

(មានត)

## ការប្រជុំលោកមេគណនិងអនុគណ

ក្នុងថ្ងៃ សុក្រ ១០ កើតនិងសៅរ៍ ១១ កើតខែកត្តិក ឆ្នាំរកាស័ក ព.ស. ២៤៩៧
ត្រូវនឹងថ្ងៃ ១០ និង ១១ ណូវ៉ែម្ប្រ៍ ១៩៥៤
(ប្រជុំក្នុងវិហារវត្តសារាវ័ន្ត បំរុលេខ ៣ ក្រុងភ្នំពេញ)

## ការប្រជុំលើកទី ១

ថ្ងៃសុក្រ ១០ កើតខែកត្តិក ឆ្នាំរកាស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃ ១០ ខែណូវែម្ប្រ៍ ឆ្នាំ ១៩៥៤ សម្តេចព្រះមហាសុមេធាធិបតី (ប៉ាក់--ហ៉ាន) សង្ឃនាយកគណៈមហានិកាយ បាននិមន្តអស់លោកជាគណៈព្រមទាំងលោកចៅអធិការវត្តគណៈមហានិកាយក្នុងក្រុងភ្នំពេញ និងលោកមេគណ - អនុគណជាច្រើនដែលមកពីខេត្តក្រៅ មកប្រជុំព្រមនៅក្នុងវិហារវត្តសារាវ័ន្តក្រុងភ្នំពេញ (ជាវត្តលំនៅរបស់សម្តេចព្រះសង្ឃនាយក) ។

វេលាម៉ោង ១៥ គឺម៉ោង ៣ រសៀល លោកអ្នកឧកញ៉ាឥន្ទ្រមហាសេនា (អ៊ិន-អ៊ី) សេនាបតីក្រសួងព្រះបរមរាជវាំង ព្រះរាជពិធីនិងធម្មការ បានអញ្ជើញទៅកាន់ទីប្រជុំនោះដែរ មានព្រះពិភក្តិធម្មការ (គុង-ហាន់) នាយកមន្ទីរក្រសួងធម្មការទៅជាមួយផង ។ លោកអ្នកឧកញ៉ាឥន្ទ្រមហាសេនាបានសំដែងសេចក្តីគោរពព្រះពុទ្ធរូបរួចហើយគោរពចំពោះសម្តេចព្រះសង្ឃនាយក និងអស់លោកព្រះថេរានុត្ថេរៈទាំងឡាយតាមលំដាប់រូបហើយ មានប្រសាសន៍ស្វាគមន៍ចំពោះទៅលោកមេគណនិងអនុគណ

ទាំងអស់ អំពីការដែលតាំងអំពីបានទទួលព្រះរាជក្រមលេខ ១៦៦ និងព្រះសង្ឃប្រកាសលេខ ១៦២ ហើយគេអស់លោកគ្រូមេគណ, អនុគណ និងអស់លោកចៅអធិការព្រមទាំងភិក្ខុសាមណេរគ្រប់វត្តបាន ទទួលប្រតិបត្តិតាមដោយស្មោះត្រង់ព្រមព្រៀង ឥតមានបព្វជិតណារឹង ទទឹងដោយហេតុណាមួយទេឬ។- លោកមេគណនិងអនុគណទាំងអស់ ឆ្លើយជំរាបថា ... ឥតមានរឹងទទឹងទេ ... ។ លោកអ្នកឧកញ៉ាអគ្គ-មហាសេនាបានមានប្រសាសន៍ ពន្យល់តាមគាមដំណើរកិច្ចការយ៉ាង សង្ខេបដោយវាចាដ៏សុភាពគួរជាទីពេញចិត្ត លុះព្រះថេរានុត្ថេរៈទាំង អស់នោះស្តាប់យល់បានដោយងាយ ។

បន្ទាប់ពីនោះមក សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក មានថេរវាចាចំពោះទៅព្រះថេរានុត្ថេរៈ មេគណ អនុគណ ទាំងអស់ បញ្ជាក់ហើយបញ្ជាក់ឲ្យអស់លោកមេគណ និងអនុគណទាំងអស់ប្រតិបត្តិ តាមព្រះរាជក្រមលេខ ១៦៦ និងព្រះសង្ឃប្រកាសលេខ ១៦២ កុំបីធ្វេស ប្រហែស កាលបើវិលត្រឡប់ពីក្រុងភ្នំពេញទៅវិញ ត្រូវពន្យល់លោក ចៅអធិការគ្រប់វត្តដែលនៅក្នុងខេត្ត របស់ខ្លួនឲ្យបានយល់ដោយសព្វ គ្រប់ កុំឲ្យមានសន្ទេះសង្ស័យដោយហេតុណាមួយ ទាំងត្រូវឲ្យប្រតិបត្តិ តាមកុំឲ្យរឹងទទឹង ... ។ សម្តេចព្រះសង្ឃនាយកមានថេរវាចាតទៅ ទៀតថា ក្នុងវេលាប្រជុំនេះ ខ្ញុំត្រូវការនិយាយដាស់តឿនក្រើនរំលឹក

អស់លោកកលអគ្គ អំពីវត្តប្រតិបត្តិខ្លះដែលខ្ញុំយល់ឃើញថាមានប្រ-
យោជន៍ ត្រូវតែបព្វជិតកល់រូបប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវតាមវិន័យ
ទំនងខាននពុំចុះ, ប៉ុន្តែខ្ញុំគម្រូវឲ្យលោកព្រះពោធិវង្សនិយាយជាជំនួសខ្ញុំ
តាមខសេចក្តីដែលខ្ញុំបានឲ្យកត់ត្រាទុកហើយជាស្រេច ។ លុះសម្តេច
មានថេរភាពជាដូច្នេះរួចហើយ បានពាក់ឲ្យព្រះសាក្យវង្ស (វែន-ប៉ុល)
សូត្រសេចក្តីព្រះរាជក្រមខ្ទឹងព្រះសង្ឃប្រកាស ឲ្យព្រះថេរានុត្ថេរៈទាំង
អស់ស្តាប់១ចប់ រួចទើបសម្តេចប្រគល់ភារៈឲ្យព្រះពោធិវង្ស (ជួន-
ណាត). និយាយសេចក្តីជាសំនៀនរំឭកជាតំណាងព្រះអគ្គលោក ។
ព្រះពោធិវង្សទទួលថេរបញ្ជាសម្តេចហើយ ក៏ថ្លែងសេចក្តីតាមខទាំង១៧
ដែលសម្តេចបានឲ្យកត់ត្រាត្រាតែជាគោលៗនោះ និយាយពង្រីក
សេចក្តីតាមដំណើរវត្តប្រតិបត្តិ ដែលមានក្នុងគម្ពីរវិន័យព្រះពុទ្ធសាសនា
ឲ្យពិស្តារបន្តិចឡើងល្មមស្តាប់បានងាយយល់ ដូចមានរាយខជាគោលៗ
ចេញលៗតទៅនេះ:

១- ត្រូវឲ្យយកចិត្តទុកដាក់ខំប្រឹងរៀនសូត្រ, ត្រូវដាស់តឿនប្រិក
ប្រៀនប្រដៅសិស្សគណឲ្យខំប្រឹងរៀន អក្សរសាស្ត្រតាមសម័យនិយម
ឲ្យសមនឹងសេចក្តីទុកបំរុងរបស់រាជការ កុំចំពាស់ កុំរឹងទទឹង, ត្រូវ
ណែនាំបង្គឹឲ្យសិស្សគណប្រឹងប្រែងរៀនធម៌វិន័យព្រះពុទ្ធសាសនា កុំ
ធ្វេសប្រហែស កុំបណ្តែតបណ្តោយឲ្យល្ងង់ខ្លៅ, បួសហើយត្រូវតែខំ

ប្រឹងរៀន បើមិនរៀនធ្វើម្ដេចនឹងចេះ? ត្រូវបំពេញកិច្ចសម្រាប់អ្នកបួស ឲ្យល្មមដល់ការទំនុកបំរុងរបស់ពួកគ្រហស្ថដែលគេគោរពយើង:... ។

២- ត្រូវឲ្យមានអភិសមាចារិកវត្ត ẽp'ĭsămacharĭkăvĕat គឺឲ្យមានវែបបទសណ្ដាប់ធ្នាប់ល្អ, ត្រូវស្លៀកដណ្ដប់ឃ្លុំត្រងស្បង់ចីពរឲ្យត្រឹមត្រូវតាមច្បាប់វិន័យ កុំឲ្យរយីករយាកខ្ជីខ្ជា, ត្រូវឲ្យមានសេចក្ដីគោរពគ្នាតាមចាស់តាមក្មេង, ត្រូវប្រព្រឹត្តការទំឲ្យទៀងទាត់តាមច្បាប់ក្នុងវិន័យវត្តក្ខន្ធក: Vĕatṭăkk'ănt'ĕakă, ត្រូវឲ្យមានការសង្រួមឥន្ទ្រិយឲ្យស្រគត់ស្រគំតាមច្បាប់វិន័យ:... ។

៣- ភិក្ខុត្រូវឧស្សាហ៍សំដែងអាបត្តិ តាមកាលដែលគួរសំដែងកាលបើមានកំហុស ពោះបីបន្តិចបន្តួច ត្រូវពិគ្រោះឧបជ្ឈាយ៍ អាចារ្យឬប្រាប់ភិក្ខុផងគ្នាឲ្យបានដឹង កុំលាក់បាំងទោសរបស់ខ្លួនឲ្យសង្ឃកើតមានសេចក្ដីរង្កៀស កុំឲ្យសមគំនិតគ្នាប្រព្រឹត្តធ្វើអំពើអាក្រក់; ត្រូវឲ្យមានសាមគ្គីសស្រោះស្មើគ្នាតាមច្បាប់ធម្មវិន័យជានិច្ច ។

៤.- ក្នុងវត្តនិមួយៗ, ដល់ថ្ងៃឧបោសថ (ក្នុង ១ ខែ ៤ ដង), ត្រូវប្រជុំគ្នាធ្វើឧបោសថកម្ម កុំខានឲ្យសោះ បើមានកិច្ចធុរៈផ្ទាល់ខ្លួនត្រូវប្រាប់ជំនុំសង្ឃក្នុងវត្តឲ្យដឹង ។ ក្នុងវត្តមួយៗបើវត្តតូច ត្រូវឲ្យមានភិក្ខុអ្នកចេះសូត្របាដិមោក្ខបាលីមាត់ទទេ យ៉ាងតិចណាស់ឲ្យបាន ៣ រូប (គាត់ទំនឹងសូត្រផ្លាស់គ្នាម្ដងៗ), គួរតែលោកចៅអធិការនឹងលោក

ត្រូវសូត្របទៈសូត្របាតិមោក្ខមាត់ទទេ ទើបសមគួរដល់ឋានៈជាអ្នកគ្រប់គ្រងវត្តនីមួយៗ ។ ភិក្ខុទាំងអស់ គួរតែឲ្យដឹងសេចក្ដីគ្រប់សិក្ខាបទទាំង ២២៧ ក្នុងបាតិមោក្ខ ព្រោះជាសិក្ខាបទសម្រាប់ភិក្ខុ, បើមិនដឹងសេចក្ដី ធ្វើម្ដេចនឹងរក្សាសិក្ខាបទទាំង ២២៧ នោះកើត . . . . . . ។

៥.– ត្រូវបញ្ញត្តហាមប្រាមឲ្យយ៉ាងតឹង កុំឲ្យភិក្ខុ-សាមណេរដើរលេងឬដើរកើតនើតក្នុងទីតំបន់ដែលពុំគួរដើរទៅ ដូចយ៉ាងទីផ្សារផ្សារជាដើម វៀរលែងតែការវេលាពិសេស គឺវេលាណាដែលមានទំនងគួរទៅមួយផង មួយការដែលនឹងខានទៅសោះពុំបាន ។

៦.–ត្រូវបញ្ញត្តហាមប្រាមឲ្យយ៉ាងតឹង កុំឲ្យភិក្ខុ-សាមណេរមានសេចក្ដីប្រកួតប្រកាន់គ្នា បើមានហេតុទាំងជ្លាក់អាក់អន់ទឹងគ្នាបន្តិចបន្តួច ត្រូវលោកដែលជាអ្នកគ្រប់គ្រង រម្ងាប់ហេតុទាំងនោះឲ្យបានស្ងប់ស្ងាត់បាត់ភ្លាមៗទៅ ទើបសាមគ្គីធម៌អាចនឹងកើតមានជានិច្ចបាន ។ ពោះភិក្ខុ-សាមណេរដែលនៅវត្តផ្សេងពីគ្នាក៏ដោយ ចាប់ដើមតាំងពីថ្ងៃនេះតរៀងទៅ ត្រូវតែមានសាមគ្គីធម៌ស្មោះស្ម័គ្រ សុកយកអាសារពាយគ្នាជាដរាប ។ ក្នុងវត្តមួយៗ ត្រូវប្រាណនៅអធិការ តាមការប្រជុំសង្ឃឲ្យរឿយៗ ដើម្បីពិគ្រោះគ្នាពីធម្មវិន័យព្រះពុទ្ធសាសនា ។

៧.– បើមានភិក្ខុណាមួយជាមនុស្សប្រព្រឹត្តអនាចារ Anackar សង្ឃស្ដីប្រដៅមិនស្ដាប់ ក៏ហួសនោះក៏មិនទាន់ដល់ថ្នាក់គួរផ្សឹកទេ គួរ

ត្រឹមតែបញ្ជាជនីយកម្ម គឺគួរដល់ការបណ្ដេញចេញ ហើយសង្ឃបាន បណ្ដេញចេញពីវត្តមួយទៅហើយ លោកចៅអធិការវត្តឯទៀតមិនត្រូវ ទទួលភិក្ខុអាក្រក់នោះឲ្យនៅក្នុងវត្តរបស់ខ្លួនឡើយ ដើម្បីឲ្យភិក្ខុអាក្រក់ នោះគ្មានទីលំនៅហើយ នឹងពេញចិត្តសឹកលែងធ្វើជាអ្នកបួសតទៅ ទៀត ។ ឯការទទួលភិក្ខុ-សាមណេរឲ្យនៅនោះ បើលុះតែមានលិខិត ព្រមទាំងសំបុត្របរិសុទ្ធិកាន់មកជាសំគាល់នោះ ទើបគួរទទួលឲ្យនៅ បាន, បើមិនដូច្នោះទេ មិនត្រូវទទួលឲ្យនៅឡើយ ។

ការប្រជុំនៅថ្ងៃសុក្រ ១០ ណូវែម្ប្រ ១៩៤៤ បានតែត្រឹមខទី ៧ នេះ ដល់វេលាល្ងាចឈប់ ក៏បញ្ឈប់ការ ១ លើកត្រឹមប៉ុណ្ណោះសិនទុក ឱកាសចាំដល់វេលារសៀលថ្ងៃស្អែកនឹងប្រជុំម្ដងទៀត ។

## ការប្រជុំលើកទី ៣

ថ្ងៃសៅរ៍ ១១ ណូវែម្ប្រ ១៩៤៤ វេលាម៉ោង ១៥ បានប្រជុំម្ដង ទៀត (ដូចថ្ងៃទី ១) ក្នុងឱកាសនោះ លោកអ្នកឧកញ៉ាអគ្គមហាសេនា ក៏បានអញ្ជើញមកកាន់ទីសន្និបាតនោះទៀតដែរ ។ វេលាម៉ោង ១៨ នឹង ៤៥ នាទី ព្រះពោធិវង្សបានថ្លែងសេចក្ដីត្រឹមខទី ៨ រៀងទៅ ដូច មានតទៅនេះ :

៨.- នៅក្នុងវត្តតែមួយជាមួយគ្នា, បើមានក្មេងឬសាមណេរដែលនៅជាសិស្សលោកចៅអធិការឬលោកគ្រូសូត្រ ឬបើវត្តធំ ទោះនៅជាសិស្សលោកភិក្ខុណាមួយក៏ដោយ, កាលបើសិស្សនោះ មានវិវាទទាស់ទែងនឹងគ្រូរបស់ខ្លួន ឬមាតាបិតារបស់សិស្សនោះទាស់អារម្មណ៍គ្នានឹងលោកជាគ្រូរបស់កូនខ្លួននោះ ដោយហេតុណាមួយ ហើយសិស្សនោះពុំសុខចិត្តនៅនឹងគ្រូដើម បែរជាទៅសុំនៅក្នុងសំណាក់លោកភិក្ខុណាមួយក្នុងវត្តជាមួយនោះវិញ, កាលបើដូច្នេះមិនត្រូវលោកភិក្ខុណាមួយហ៊ានទទួលឲ្យសិស្សនោះនៅឡើយ; ត្រូវលោកចៅអធិការនឹងលោកគ្រូសូត្រនិយាយផ្សះផ្សាសម្រុះសម្រួលយ៉ាងណាឲ្យគ្រាន់តែបានសុខចិត្តសះជានឹងគ្នាដូចដើមវិញ ។

៩.- តែងតែមានខ្លះមកហើយ, ក្នុងវត្តមួយជាមួយគ្នា, លោកគ្រូសូត្រមិនត្រូវអធ្យាស្រ័យគ្នានឹងលោកចៅអធិការ មិនព្រមយកលោកចៅអធិការនោះធ្វើជាឧបជ្ឈាយ៍បំបួសសិស្សរបស់ខ្លួន ក៏នាំយកសិស្សនោះទៅបំបួសឯវត្តដទៃ ហើយនាំយកសិស្សនោះមកឲ្យនៅក្នុងវត្តខ្លួននោះវិញ សិស្សនោះមិនទទួលស្តាប់បង្គាប់លោកចៅអធិការ; ដូច្នេះមិនត្រូវទេ ត្រូវហាមផ្តាច់កុំឲ្យមានកិរិយាយ៉ាងនេះតទៅទៀត ។ ការបំបួសកុលបុត្រនេះ ត្រូវតែបញ្ញត្តបើកឲ្យយ៉ាងតឹង កុំឲ្យខុសអំពីព្រះវិន័យបព្វជ្ជាខន្ធក: Băp pĕachea K'ănt'ĕak ទីងកបញ្ញត្ត ។

១០ — លោកមេគណនិងអនុគណ ត្រូវយកចិត្តទុកដាក់ ចាត់ការត្រួតត្រាឲ្យម៉ឺងម៉ាត់ ទៅលើវត្តទាំងប៉ុន្មានដែលនៅក្រោមបង្គាប់ខ្លួន កុំបណ្ដែតបណ្ដោយឲ្យមានអធិករណ៍កើតឡើងរឿយៗ, បើមានអធិករណ៍ណាមួយកើតឡើង ត្រូវប្រញាប់រម្ងាប់អធិករណ៍នោះឲ្យស្ងប់ភ្លាមៗ ទៅកុំឲ្យមានការប្ដឹងផ្ដល់ដល់រាជការគណបក្ស រៀរលែងតែហេតុអធិករណ៍ណាមួយធំដុំ ដែលតាក់តែងដោយច្បាប់គណបក្សហើយបព្វជិតពុំអាចនឹងរម្ងាប់បាន ។

១១.- ត្រូវហាមប្រាមឲ្យលោកចៅអធិការគ្រប់វត្តចេះថែរក្សារបស់ជាគរុភណ្ឌផ្សេងៗ ដែលជាកេរ្តិ៍សម្រាប់វត្តមួយៗ កុំឲ្យវិនាសអន្តរាយដោយហេតុធ្វេសប្រហែស, ត្រូវមានបញ្ជីកត់ត្រា របស់សម្រាប់វត្តឲ្យទៀងទាត់, ត្រូវប្រើប្រាស់តែជាគរុភណ្ឌកុំឲ្យឥតសណ្ដាប់ធ្នាប់ កុំឲ្យដាក់រទាំង កុំឲ្យខុសអំពីច្បាប់វិន័យសេនាសនក្ខន្ធកៈ Senasănăk-k'ănt'ĕakă ជាដើម ។

១២.- ត្រូវហាមប្រាមកុំឲ្យភិក្ខុ-សាមណេរលក់ដូររបស់ដែលមានទំនងខុសខាងវិន័យបញ្ញត្តិ, កុំឲ្យជាវរបស់ដែលពុំគួរទិញ ដូចយ៉ាងរបស់ចោរជាដើមកុំឲ្យប្រកបកិច្ចការធ្វើរបស់លក់ដូរដូចគ្រហស្ថ, កុំឲ្យចិញ្ចឹមសត្វពាហនៈខុសទំនងពីវិន័យបញ្ញត្តិ ។

១៣.- ត្រូវហាមប្រាមឃាត់ម៉ឺងម៉ាត់ កុំឲ្យភិក្ខុ - សាមណេរ ទទួលបញ្ញើរបស់គ្រហស្ថ ទុកដាក់ថែរក្សាក្នុងលំនៅ កុំឲ្យហ៊ាន បំបាត់មុខពន្ធព្រះរាជអាករ មានការរំលងគយនិងការបំបាំងមុខពន្ធនៃព្រៃព្រឹក្សាជាដើម ។

១៤.- កាលណាបើមានកិច្ចការអ្វីមួយដែលត្រូវប្រើប្រាស់យាននៃកង-- ការគណចក្រ ត្រូវចាត់គណាចារ្យសម្រាប់វត្តឲ្យទៅជួបឬឲ្យទៅនិយាយ ការជំនួស មិនត្រូវបព្វជិតទៅដោយខ្លួនឯងទេ វៀរលែងតែការចម្បង ដែលមិនទាស់ខុសនឹងបញ្ញត្តិ ។

១៥.- ត្រូវហាមប្រាមកុំឲ្យភិក្ខុ-សាមណេរផ្ញើសំបុត្រស្នេហ៍ទៅវិញ ទៅមកនឹងគ្នា ដោយសំបុត្រនោះនាំនូវសេចក្ដីទាស់ខុសនឹងច្បាប់បញ្ញត្តិ ។

១៦.- ត្រូវឲ្យលោកចៅអធិការគ្រប់វត្តយកចិត្តទុកដាក់ចាត់ការសំ-អាតវត្តអារាមមានវិហារជាដើមឲ្យស្អាតជានិច្ច កុំបណ្ដែតបណ្ដោយឲ្យទីវត្តមិនស្អាតមិនរុងរឿង, ត្រូវចាត់ការរៀបចំទីវត្តទាំងមូលឲ្យមានរបៀបរៀបរយល្អ ឲ្យត្រូវបែបបទតាមច្បាប់សុភាពិបាលព្រមទាំងរបៀបដែលគួរជាទីពេញចិត្តកើតសេចក្ដីជ្រះថ្លានៃជននានាជាតិ ឲ្យសមនឹងពាក្យដែលហៅថា "អារាម" ឬ "វត្តអារាម" ដែលប្រែថា "សួន-ច្បារ" ឬ ថា "វត្តជាទីរីករាយសប្បាយនៃមហាជន" ។

១៧.- មានលោកចៅអធិការទីពីរលោកគ្រូសូត្រខ្លះ ខំប្រឹងរៀនសូត្រព្រមទាំងប្រព្រឹត្តប្រតិបត្តិកាន់តាមលំអានធម៌វិន័យនិងច្បាប់បញ្ញត្តិ ចំណេះបានតែខ្លួនមួយប៉ុណ្ណោះ បណ្ដែតបណ្ដោយឲ្យភិក្ខុ-សាមណេរ ដែលនៅក្នុងវត្តខ្លួនខ្វល់ប្រហែស ប្រព្រឹត្តខ្ជិលតាមតែបាន ឥតសណ្ដាប់ធ្នាប់ ចង់ធ្វើអ្វី ពេះតែធ្វើទៅតាមអំពើចិត្ត ។ ការបណ្ដែតបណ្ដោយនោះតើយ៉ាងនេះ ចូលក្នុងដំណើរធ្វេសប្រហែស ចូលក្នុងបទល្មើសច្បាប់ ចូលក្នុងបទស៊ីគ្រលុក, មិនប្រសើរទេ មិនពេញនាទីជាអ្នកគ្រប់គ្រងសិស្សគណទេ ។ ត្រូវលោកមេគណនិងអនុគណទាំងអស់រំឭកដាស់តឿនឲ្យបោះបង់កិរិយាដូច្នោះចេញ ។

លុះព្រះពោធិវង្សថ្លែងសេចក្ដីដាស់តឿនក្រើនរំឭកទាំងនេះចប់ហើយ, សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក មានថេរវាចាបញ្ជាក់ថែមទៀតថា សេចក្ដីដែលលោកព្រះពោធិវង្សនិយាយមកហើយនេះ គឺនិយាយតាមកំណត់កត់ត្រាដែលខ្ញុំជាសង្ឃនាយកបានចាត់ឲ្យរៀបរៀងទុកពីថ្ងៃមុនគ្រាន់តែឲ្យគេដាក់ជាគោលៗ (រៀងតាមលំដាប់លេខពីរទី១ ដល់ខទី ១៧) ចំពោះពីគំនិតយល់ឃើញរបស់ខ្ញុំ, ត្រូវលោកមេគណអនុគណនិងចៅអធិការទាំងអស់ប្រតិបត្តិតាម, កាលបើអស់លោកបានប្រតិបត្តិកាន់តាមហើយ ខ្ញុំសូមប្រគេនពរដល់អស់លោក សូមឲ្យអស់

លោកបានប្រកបដោយពរ៤ ប្រការ គឺ អាយុ, វណ្ណៈ, សុខៈ, ពលៈ, ayŭ vĕanna, sŏk'ă, pĕalĕa, ព្រមទាំងឲ្យមានសេចក្ដីល្អគាស់ចំរើនក្នុងធម៌វិន័យព្រះពុទ្ធសាសនាតវែងឆ្ងាយទៅ! ព្រះថេរានុត្ថេរៈទាំងអស់ក៏ទទួលពរពីសម្ដេចថា សាធុ! ព្រមគ្នា ៣

លំដាប់បន្ទាប់ពីនោះមក សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកនៃព្រះសង្ឃទាំងអស់ក្នុងទីប្រជុំនោះ បានតាំងសច្ចាធិដ្ឋានផ្សាយព្រះរាជកុសលថ្វាយចំពោះព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្ដេចព្រះនរោត្តម-សីហនុ វរ្ម័ន ធម្មិកមហារាជាធិរាជ ព្រះចៅក្រុងកម្ពុជាធិបតី ព្រមទាំងជូនកុសលចំពោះទៅលោក ហ្សង់-ដឹគូ ឲ្យគូវែរណឺរហ្សេណេរ៉ាល់ប្រទេសឥណ្ឌូចិន និងលោក ហ្សក-គោរេរ ឲ្យរេស៊ីដង់ស៊ុបេរីយើរប្រទេសខ្មែរ សូមព្រះករុណាជាម្ចាស់ជីវិតនិងលោក ឥស្សរាធិបតីទាំង២ បានប្រកបដោយសេចក្ដីចំរើននិងសួស្តីគ្រប់ប្រការ!

តមកទៀត បានប្រកាសសេចក្ដីសច្ចាធិដ្ឋានសំបួងសួងសូមឲ្យមហានគរបារាំងសែសបានរួចស្រឡះពីគ្រោះថ្នាក់ទុក្ខភ័យ, សូមឲ្យបានល្អគាស់ចំរើនដោយឆាប់រហ័សរួសរាន់ទាន់សម័យ! សូមឲ្យសហព័ន្ធឥណ្ឌូចិន បានសេចក្ដីសុខក្សេមក្សាន្ត! សូមឲ្យកម្ពុជរដ្ឋរួចផុតពីគ្រោះថ្នាក់ភ័យអន្តរាយ កុំបីប្រទះប៉ះពាល់ឧបសគ្គណាមួយឡើយ!

បន្ទាប់មកទៀត ព្រះសង្ឃទាំងអស់បានជូនពរចំពោះលោកអ្នកកញ្ញា អគ្គមហាសេនា (អ៊ឹង-អ៊ី) ថា សូមឲ្យលោកបានប្រកបដោយសិរីសួស្តីទាំង ៤ ប្រការគឺ: អាយុ, វណ្ណៈ, សុខៈ, ពលៈ!

បន្ទាប់ពីនោះមកទៀត ព្រះសង្ឃទាំងអស់បានសូត្រធម៌ ជយន្តោ chĕayĕantô ចំរើនសិរីសួស្តីជយមង្គលតាមទំនៀមទំលាប់នៃពុទ្ធសាសនិកជន ។

ជាសង្ខេបនៃការប្រជុំទាំង ២ លើកតែប៉ុណ្ណេះ ។

---

សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ។

ហត្ថលេខា: ប្រាក់-ហ៊ិន

## ព្រះរាជាគណៈជាក្រុមជំនុំ

ព្រះពោធិវង្ស
ហត្ថលេខា: ជួន-ណាក

ព្រះអរិយវង្ស
ហត្ថលេខា: អ៊ិត-គុប

ព្រះមហាវិមលធម្ម
ហត្ថលេខា: ហួត-តាត

ព្រះសមាធិធម្ម
ហត្ថលេខា: អ៊ុ-ស៊ូ

ព្រះធម្មឃោសាចារ្យ
ហត្ថលេខា: មៀង

ព្រះញាណសំវរ
ហត្ថលេខា: ផង់ កុយ

ព្រះសាក្យវង្ស

ហត្ថលេខា: ខែន-ប៊ុល

ព្រះធម្មវង្ស

ហត្ថលេខា: ពៅ-ហ៊ិន

ព្រះពុទ្ធវង្ស

ហត្ថលេខា: ឈុន

ព្រះឥន្ទមុនី

ហត្ថលេខា: ពៅ-នេត

បានចំឡងត្រឹមត្រូវហើយ

ព្រះពិតក្កធម្មការ ។

អរិយសច្ចជាពុទ្ធភាសិត

លោកគ្រូអាចារ្យ ប៉ាង-ខាត់ ស្រង់ប្រែចេញពីបាលីព្រះត្រៃបិដក

## កថាមុខ

ព្រះពុទ្ធសាសនាទាំងមូល មានចតុរារិយសច្ចជាកំពូល, ធម៌គ្រប់យ៉ាង សុទ្ធតែសង្គ្រោះរួមចុះក្នុងចតុរារិយសច្ចទាំងអស់, សេចក្ដីប្រតិបត្តិគ្រប់បែបដែលមានប្រាកដក្នុងគម្ពីរទាំងឡាយ ក៏តែងមានឡើងដើម្បីសេចក្ដីចេះដឹងអរិយសច្ចដោយប្រាជ្ញា ។ កាលណាបុគ្គលចេះដឹងអរិយសច្ចដោយប្រាជ្ញាដល់ទីបំផុតហើយ បុគ្គលនោះក៏ដោះរួចចាកអាសវៈ បានជាអ្នកធ្វើទីបំផុតនៃសេចក្ដីទុក្ខឲ្យប្រាកដបាន ហើយរួចចាកសេចក្ដីទុក្ខយ៉ាងដាច់ខាត មិនត្រឡប់កើតមានសេចក្ដីទុក្ខតទៅទៀត ព្រោះចិត្តរួចស្រឡះចាកសភាវធម៌ដែលធ្លាប់ប្រកាន់ស្អិតមាំយូរយារហើយ ។ អរិយសច្ចជាកំពូលធម៌ ការចេះដឹងអរិយសច្ច ជាកំពូលនៃព្រហ្មចរិយៈ ការប្រព្រឹត្តដើម្បីឲ្យត្រាស់ដឹងអរិយសច្ចដោយប្រាជ្ញា ជាកំពូលនៃការប្រព្រឹត្តទាំងមូល ។

ពាក្យថា "អរិយសច្ច" ប្រែថា សេចក្ដីពិតដ៏ប្រសើរ, ជាសេចក្ដីពិតដែលមិនចេះប្រែប្រួល ជាសេចក្ដីពិតដែលធ្វើអ្នកចេះដឹងឲ្យរួចស្រឡះចាកទុក្ខបាន ។ ឯសេចក្ដីពិតនោះមានសេចក្ដីសំគាល់ប្រែន

ប្រការ សេចក្តីពិតបែបខ្លះ ដូចលោកនេះមានព្រះអាទិត្យកើតឡើង ឬ មានថ្ងៃមានយប់ សេចក្តីពិតនេះមិនទៀងទាត់បិតថេរទេ ជួនកាលយុគខ្លះអាចផ្លាស់ប្តូរទៅជាបែបផ្សេងៗ ដោយប្រព្រឹត្តកន្លងទៅនៃកាលវែងៗ សេចក្តីពិតផ្សេងៗ ក្រៅពីអរិយសច្ច ជាសេចក្តីពិតដោយសន្មតនៃលោក សូម្បីសេចក្តីពិតដែលអ្នកវិទ្យាសាស្ត្រខាងវិត្តកន្លងបច្ចុប្បន្ន-កាលគេរកឃើញកើតឡើងបាន ក៏សុទ្ធតែជាសេចក្តីពិតដែលនៅក្រោមអំណាចសេចក្តីទុក្ខនៃវដ្តសង្សារ ។ ចំណែកសេចក្តីពិតគឺអរិយសច្ចនោះ មិនផ្លាស់ប្តូរគ្រប់យុគគ្រប់កាលនៃលោក ជាធម្មជាតិគួរជីវិតដែលស្វះស្វែងរកសេចក្តីសុខជាក់ខ្លួន ហើយមិនមានផ្លូវដទៃដែលនាំឲ្យបានសមតាមសេចក្តីប្រាថ្នា ក្រៅពីការស្វែងរកសេចក្តីពិតនេះទេ, លក្ខណៈទាំងអស់នេះឈ្មោះថា " សេចក្តីពិតដ៏ប្រសើរ " ។

ក្នុងលោកនេះ ឬ លោកឯណាៗ កប់ចំនួនដោយពាន់នៃលោកក៏ដោយ មិនមានអ្វីឲ្យប្រសើរជាង សេចក្តីរំលត់ទុក្ខ" ។ ការរំលត់បាត់សេចក្តីទុក្ខបាន ក៏ព្រោះដឹងសេចក្តីពិតដ៏ប្រសើរ គឺដឹងរូបទុក្ខ រូបហេតុដែលនាំឲ្យកើតទុក្ខ រូបធម៌ដែលរលត់ហេតុនៃទុក្ខ និងរូបវិធីដែលនាំឲ្យរលត់ហេតុនៃសេចក្តីទុក្ខ ។ ធម៌ទាំង ៤ ប្រការនេះហៅថា "ចតុរារិយសច្ច" ដែលព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ មិនទ្រង់ប្រាប់ពីដែលប្រសើរក្រៅលែងជាងសេចក្តីពិត ៤ ប្រការនេះឡើយ ហើយសត្វ

គ្រប់រូប មិនមានការដឹងសេចក្ដីពិតស៊ូជទៃ ទៀតក្រៅលែងជាងសេចក្ដីពិតនេះទៅទៀតទេ ។

ដោយហេតុដូចបានពោលមកនេះ ខ្ញុំយល់ឃើញថា អរិយសច្ចជាវិជ្ជាដែលត្រូវសិក្សា សម្រាប់ជាសម្បត្តិប្រចាំជីវិត ប្រសើរជាងការចេះដឹងអ្វីៗដទៃទាំងអស់ ដែលគ្រាន់តែជាការលលួងឲ្យជីវិតកើតកើនទៅកន្លងមួយថ្ងៃៗទទេប៉ុណ្ណោះ ។ មែនពិត, សេចក្ដីពិតគឺអរិយសច្ចនោះមានតែមួយគឺ "ការរួចទុក្ខ" ដោយការរលត់តណ្ហា ដែលជាហេតុនៃទុក្ខចេញបានដោយមជ្ឈិមាបដិបទា, តែថាពាក្យអធិប្បាយរបស់សេចក្ដីពិតទាំងអស់នេះ មានបរិករសេចក្ដីដែលជាប់ទាក់ទងគ្នាទៅវិញទៅមកជាច្រើនដើម្បីឲ្យដឹងសេចក្ដីពិតដ៏ត្រឹមត្រូវ ហើយល្អិតល្អន់ច្បាស់លាស់ ។ ដើម្បីឲ្យសម្រេចប្រយោជន៍ទាំងអស់នេះ ខ្ញុំទើបព្យាយាមរួបរួមអរិយសច្ចចំពោះព្រះពុទ្ធភាសិត ដែលទ្រង់ត្រាស់ដោយព្រះអង្គឯង ឬពាក្យជាបរិករផ្សេងៗ ចេញពីគម្ពីរព្រះត្រៃបិដក ដែលជាគួបាលីសុទ្ធ ចាស់ជាងគម្ពីរឯទៀតទាំងអស់ បើអ្នករៀនត្រូវការពាក្យអធិប្បាយដើងភាសា ឬបរិយាយសេចក្ដីផ្សេងៗ អាចស្វះស្វែងទៅរកក្នុងគម្ពីរនោះៗ ដោយខ្លួនឯងបានដោយស្រួល ។

សូម្បីខ្ញុំបានតាំងចិត្តចាប់ធ្វើការនេះមកយូរហើយ ដោយសេចក្ដីប្រយ័ត្នប្រយែងយ៉ាងម៉ឺងម៉ាត់ ក៏គង់នឹងមានការភ្លាំងភ្លាត់ខ្វះមិនខាន

ដោយសតិបញ្ញាខ្ញុំមិនគ្រប់គ្រាន់ ។ ជាបើមាន ខ្ញុំសូមតាំងសុភាសិតមួយបទថា "ការភ្លាំងភ្លាត់ជាធម្មតារបស់អ្នកសរសេរ ការឲ្យអភ័យជាធម្មតារបស់អ្នកមើល" ប៉ុណ្ណោះក៏ចប់ ។

ខ្ញុំមានសេចក្ដីបំណងយ៉ាងធ្ងន់ថា បើអស់លោកទាំងឡាយបានមើលធម៌អរិយសច្ចនេះហើយ សូមជួយស្វះស្វែងរកសេចក្ដីពិតក្នុងរឿងនេះមកសរសេរថែមទៀតឲ្យបានរឿងនេះសម្បូណ៌ក្រៃលែងតរៀងទៅរហូតទាល់តែឲ្យការបែបនេះដល់ទីបំផុតបាន ។

សម្រាប់ពុទ្ធភាសិតដែលទ្រង់ត្រាស់ដល់រឿងនេះ ដែលមានប្រាកដនៅក្នុងគម្ពីរព្រះត្រៃបិដក ខ្ញុំបានរួបរួមចងក្រង បានរៀបគ្រោងរឿងនិយាយសុទ្ធតែសេចក្ដីដែលទាក់ទងដោយចតុរិយសច្ច ដូចតទៅនេះ:

១- ទុក្ខអរិយសច្ច សេចក្ដីពិតដ៏ប្រសើរគឺទុក្ខ ។

២- សមុទយអរិយសច្ច សេចក្ដីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ ។

៣- និរោធអរិយសច្ច សេចក្ដីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរលត់ទុក្ខ ។

៤- មគ្គអរិយសច្ច សេចក្ដីពិតដ៏ប្រសើរគឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

អរិយសច្ចទាំង ៤ ប្រការនេះ បែកជា ៥ បទគឺ ១- សត្វលោកដឹងចតុរិយសច្ច ២- ដរិកមនុស្សដឹងចតុរិយសច្ច ៣- ព្រះពុទ្ធ-

អត្ថនិទ្ទេសចតុក្កអរិយសច្ច ៤- ការត្រាស់ដឹងអរិយសច្ចមិនមែនជាការផុតវិស័យ ៥- ប្រភេទអរិយសច្ច ។

គន្ថនេះ ខ្ញុំពេញចិត្តនិយាយសុទ្ធតែអរិយសច្ចដែលជាពុទ្ធភាសិត គឺប្រែត្រង់តាមគម្ពីរបាលី បើមានតួអក្សរប្លែកគ្នា គឺជាសេចក្តីរបស់ខ្ញុំ ជាអ្នកសរសេរ គឺត្រង់សេចក្តីណាមួយដែលខ្ញុំពន្យល់ដើម្បីឲ្យជាប់គ្នាជាសេចក្តីប៉ុណ្ណោះ ហើយខ្ញុំឲ្យឈ្មោះសៀវភៅនេះថា "អរិយសច្ចជាពុទ្ធភាសិតឬអរិយសច្ចតថាគត" មួយទៀតខ្ញុំយល់ឃើញថា សំនួនភាសាឬមួយរបៀបប្រយោគដែលមាននៅក្នុងព្រះត្រៃបិដក មិនមែនជាពុទ្ធ-ភាសិតដែលទ្រង់ត្រាស់ទេសនាបែបជាប្រយោគដូច្នេះៗ ទេ ឯដែលហៅថាពុទ្ធវចនៈ សំដៅយកត្រង់តែសេចក្តីដែលទ្រង់ត្រាស់ទេសនាប៉ុណ្ណោះឯង ហេតុនោះដែលខ្ញុំថា "អរិយសច្ចជាពុទ្ធភាសិតឬអរិយ-សច្ចតថាគត" នោះ ចំពោះតែរូបសេចក្តីដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទេសនាហើយខ្ញុំមិនបានផ្លាស់ប្តូរទៅយ៉ាងណាឡើយ ខ្ញុំទុកឲ្យនៅតាមសភាពដើមទាំងអស់ ។

សូមឲ្យផលកុសលដែលកើតអំពីការផ្សាយធម៌នេះ ជាបដិបត្តិបូជាចំពោះព្រះដ៏មានព្រះភាគ អស់កាលទាំងពួងហោង ។

វត្តប្រាង្គណ៍ថ្ងៃអង្គារ ៧ រោចខែភទ្របទ ឆ្នាំមមែបញ្ចស័ក ព. ស. ២៤៨៦ ត្រូវនឹង
ថ្ងៃ ២៨ សេប្តេម្ប្រ៍ ឆ្នាំ ១៩៤៣ ភិក្ខុ ប៉ិ. ខាត់ (មានត)